ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល
NEAK KLOAMMEUL

លេខ ៤២ ឆ្នាំទី១២ ចេញថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០

## យុត្តិធម៌ក្នុងការបោះឆ្នោតត្រូវផ្ដោតលើ ឱកាសស្មើគ្នារបស់អ្នកប្រកួតប្រជែង




## មាតិកា


★ អធិប្បាយលេខនេះ: ដំណោះស្រាយ និងភាពអត់ឱនខាងនយោបាយចំពោះទំនាស់ផលប្រយោជន៍............. ១
★ របាយការណ៍ឆ្នាំ ២០០៩ ស្ដីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា......................... ៣
★ មូលនិធិគណបក្សនយោបាយ និងអំពើពុករលួយរបស់គណបក្សនយោបាយ នៅអាស៊ីខាងកើត ............... ១១
★ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងរដូវកាលប្រជុំពេញអង្គ.................................................. ១៥
★ កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ............................................................................................... ១៩


អ្នកឃ្លាំមើល : ការផ្សព្វផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា


សិក្ខាសាលា E-Campaigning and Social Media for Civil Society រៀបចំដោយខុមហ្វ្រែល, ថ្ងៃទី ១-៣ ខែមិថុនា ឆ្នាំ២០១០ នៅសណ្ឋាគារ Imperial Garden







អធិប្បាយលេខនេះ

# ដំណោះស្រាយ និងភាពអត់ឱនខាងនយោបាយចំពោះទំនាស់ផលប្រយោជន៍ តាមរយៈការបញ្ចេញមតិពិតជាសំខាន់

(បើមិនដូច្នេះ នឹងមានផលប៉ះពាល់លើដំណើរការប្រជាធិបតេយ្យ និងការបោះឆ្នោតឆ្នាំ ២០១២ និង ២០១៣)

ប្រតិកម្មតប និងការប្រើឥទ្ធិពលអំណាចរបស់រដ្ឋក្នុងការរិតត្បិតសេរីភាពបញ្ចេញមតិរិះគន់ បានរុញគណបក្សប្រឆាំង និងយោបល់ទិះតៀនទាំងឡាយឲ្យនៅឆ្ងាយពីទីលានប្រកួតប្រជែងប្រជាធិបតេយ្យ ពិសេសការត្រៀមខ្លួនសម្រាប់ការបោះឆ្នោតប្រកួតប្រជែងដោយសេរី និងយុត្តិធម៌ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣ ខាងមុខ។



ប្រជាធិបតេយ្យ សេរីពហុបក្ស និងការប្រកួតប្រជែងបោះឆ្នោតដោយយុត្តិធម៌ មិនអាចបណ្តាលឲ្យស្ថានការណ៍ដែលអ្នកនយោបាយ និងសកម្មជនគណបក្សប្រឆាំងសំខាន់ៗ សុទ្ធតែងាយនឹងក្លាយជាចំណុចស៊ីបនយោបាយ ដោយរងការចោទប្រកាន់តាមប្រព័ន្ធតុលាការ ជាក់ស្តែងដូចជា ករណីតំណាងរាស្ត្រ និងជាមេដឹកនាំគណបក្សជំទាស់ ឯកឧត្តម **សម រង្ស៊ី** តំណាងរាស្ត្រស្ត្រីដ៏មានឥទ្ធិពល លោកជំទាវ **មូរ សុខហួរ** និងសកម្មជនគណបក្សសមរង្ស៊ីនៅខេត្តកំពង់ធំ ចំនួន ៤ រូប ជាដើម។

ជម្លោះនយោបាយដោយការបញ្ចេញមតិ ដែលប្រើប្រាស់ប្រព័ន្ធតុលាការដោះស្រាយ មិនមានថ្ងៃចប់ទេ ហើយការនិយមនិន្នាការរបៀបនេះនឹងនាំឲ្យខូចខាតផលប្រយោជន៍ប្រទេសជាតិ និងពលរដ្ឋ។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីទាំងពីររូប [ឯកឧត្តម សម រង្ស៊ី និង លោកជំទាវ មូរ សុខហួរ] អាចនឹងប៉ះពាល់ដល់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតនៅឆ្នាំ ២០១២ និង២០១៣ ខាងមុខ ប្រសិនបើតុលាការកម្ពុជា អនុវត្តវិធានការបង្ខំដាក់ពន្ធនាគារ។ រូបភាពនៃដំណើរការបោះឆ្នោតនៅពេលមុខ នឹងមិនមានទីលានប្រកួតយុត្តិធម៌ និងគ្មានកិត្យានុភាពពេញលេញ។

**ករណីឯកឧត្តម សម រង្ស៊ី** ៖ តុលាការខេត្តស្វាយរៀងបានកាត់ទោសកំបាំងមុខឲ្យឯកឧត្តម សម រង្ស៊ី ជាប់ពន្ធនាគារចំនួន ២ឆ្នាំ កាលពីថ្ងៃទី២៧ មករា ២០១០ ពីបទបំផ្លាញទ្រព្យ **សម្បត្តិសាធារណៈ និងញុះញង់ឲ្យមានការរើសអើងជាតិសាសន៍** ដោយសារតែតំណាងរាស្ត្ររូបនេះ បានដឹកនាំប្រជាពលរដ្ឋមួយចំនួនដកតម្រុយបង្គោលព្រំដែនកម្ពុជា-វៀតណាម លេខ ១៨៥ កាលពីថ្ងៃទី២៩ តុលា ២០០៩។ ក្តីមួយនេះ បានទាញពលរដ្ឋមួយចំនួនឲ្យមកពាក់ព័ន្ធនឹងការដាក់ពន្ធនាគារ ដោយអាចបន្សល់ត្រឹមបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ដែល មិនអស់ចិត្តប៉ុណ្ណោះ។ សាលាឧទ្ធរណ៍បានកំណត់យកថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១០ ដើម្បីបើកសវនាការជំនុំ ជម្រះ លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងលើករណីបំផ្លាញតម្រុយបង្គោលព្រំដែនកម្ពុជា-វៀតណាម នៅស្រុកចន្ទ្រា



រូបភាព ៖ (ខុមហ្វ្រែល)
(ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី)



ខេត្តស្វាយរៀង។

ជាគោលការណ៍ក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌ ធាតុផ្សំបី មាន នីត្យានុកូល សត្យានុម័ត និង អត្តនោម័ត ត្រូវតែលើកយកមកសំអាងដោយតុលាការមានសមត្ថកិច្ចក្នុងការចោទប្រកាន់។ ចរឹតនៃបទល្មើស **ចំណងហេតុនិងផល ព្យសនកម្ម និងអំពើបង្កហេតុ** នឹងត្រូវថ្លឹងថ្លែងដើម្បីដោះ ឬដាក់បន្ទុកចុងចោទ។ ច្បាប់តម្រូវឲ្យបទចោទទាំងពីរត្រូវតែថ្លឹងថ្លែងទៅលើចេតនាធ្វើឲ្យខូចខាត និងទំហំនៃការខូចខាត មុននឹងធ្វើសេចក្តីសម្រេចផ្តន្ទាទោសកម្រិតអតិបរមាដាក់ពន្ធនាគារ ៣ ឆ្នាំ។ ជាការអនុវត្តជាក់ស្តែង ភស្តុតាង «តម្រុយបង្គោលព្រំដែនកម្ពុជា-វៀតណាម លេខ ១៨៥» ដែលជាធាតុគន្លឹះដើមចមនៃរឿងក្តីមួយនេះ មិនត្រូវបានយកមកដេញដោលឲ្យបានហ្មត់ចត់នៅពេលអង្គសេចក្តីទេ។ **តើតម្រុយបង្គោលព្រំដែនពិតជាត្រូវបានដាំ ឬដកចេញដោយខុសច្បាប់ឬ** ?

ការប្តឹងផ្តល់នេះ កាន់តែធ្វើឲ្យសាធារណៈមតិជាតិ និងអន្តរជាតិ មានការព្រួយបារម្ភអំពីបញ្ហា នយោបាយថ្មីៗនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងលំហប្រជាធិបតេយ្យ និងតួនាទីរបស់អ្នកតំណាងរាស្ត្រ ជាពិសេសអ្នកតំណាងរាស្ត្រនៃគណបក្សជំទាស់ ខណៈពេលដែលបញ្ហាជាតិ រួមទាំងបញ្ហាព្រំដែន កំពុងតែត្រូវការឲ្យមានការចូលរួមចំណែកដោះស្រាយពីអ្នកនយោបាយមកពីគ្រប់និន្នាការនយោបាយទាំងអស់។

ប្រសិនបើមិនមានកិច្ចសម្របសម្រួលតាមផ្នែកនយោបាយណាមួយ ឬការប្រទានលើកលែងទោសដោយព្រះមហាក្សត្រ សេចក្តីសម្រេចរបស់តុលាការខេត្តស្វាយរៀង កាត់ទោសឯកឧត្តម សម រង្ស៊ី ដាក់ពន្ធនាគារ ២ ឆ្នាំ បានដាក់ចំណាត់ថ្នាក់ទម្ងន់ទោសនៃបទល្មើស នៅត្រឹម បទមជ្ឈឹម ដោយផ្អែកតាមច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ១៩៩២ ទោះបីជាយ៉ាងនេះក្តី ទម្ងន់ទោសប៉ុណ្ណេះ ល្មមអាចនឹងឲ្យតំណាងរាស្ត្ររូបនេះបាត់បង់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត នៅឆ្នាំ២០១៣ ខាងមុខ ព្រោះយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពី លក្ខន្តិកៈតំណាង រាស្ត្រ ៖ តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ សម្រេចថាជា **ទណ្ឌិតជាប់ពន្ធនាគារ** ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា។



រូបភាព ៖ អ៊ីនធើណែត
(លោកជំទាវ មូរ សុខហួរ តំណាងរាស្ត្រគណបក្សសមរង្ស៊ី និងលោកស្រី Hillary Clinton Clinton រដ្ឋមន្ត្រី ក្រសួងការបរទេសសហរដ្ឋអាមេរិក ៖ The Kennedy Center 19 March,2009)

**ករណីលោកជំទាវ មូរ សុខហួរ** ៖ ជាលទ្ធផល តុលាការកំពូលបានសម្រេចតម្កល់ទុកសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចឲ្យលោកស្រី មូរ សុខហួរ ចាញ់ក្តី ក្នុងបណ្តឹងបទបរិហារកេរ្តិ៍ របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្គាប់ឲ្យបង់ប្រាក់ពិន័យ និងសងជំងឺចិត្ត **១៦ លាន ៥ សែន រៀល** កាលពីថ្ងៃពុធ ទី២ ខែមិថុនា ឆ្នាំ២០១០កន្លងទៅ។ ដើម្បីអនុវត្តសេចក្តីសម្រេចតុលាការ សាលាដំបូងរាជធានីភ្នំពេញបានដាក់កំហិតឲ្យលោកស្រី មូរ សុខហួរ សងជំងឺចិត្តសម្តេច ហ៊ុន សែន ជាទឹកប្រាក់ **៨ លាន រៀល** និងប្រាក់ពិន័យ **៨,៥ លាន រៀល** ទៅឲ្យរតនាគារ ឲ្យបានមុនថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១០ ដើម្បីចៀសវាងវិធានបង្ខំរូបកាយ។ ទោះបីជាមានមតិថា ត្រូវបង្ខំរូបកាយដោយដាក់ពន្ធនាគារ បើសិនជាមិនបង់ប្រាក់ពិន័យ និងសងជំងឺចិត្ត មេធាវីដើមចោទ លោក **គី តិច** បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា លោកបានដាក់ពាក្យស្នើឲ្យតុលាការរាជធានីភ្នំពេញ កាត់ប្រាក់ខែរបស់លោកស្រី មូរ សុខហួរ ជំនួសឲ្យការចាប់ឃុំខ្លួន ខណៈ ដែលតំណាងរាស្ត្រស្ត្រីរូបនេះ មិនព្រមបង់ប្រាក់ពិន័យ និងសំណងជំងឺចិត្ត។

តទៅទំព័រ ៥

# របាយការណ៍ឆ្នាំ ២០០៩ ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា

នៅក្នុងឯកសារនេះ ខុមហ្វ្រែល ពិនិត្យមើលស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ដែលទាក់ទងនឹងប្រជាធិបតេយ្យ និងការបោះឆ្នោត សេរីភាពស្មូល អភិបាលកិច្ចល្អ កំណែទម្រង់ច្បាប់ និងតុលាការ និងពិពណ៌នាអំពីសកម្មភាពជាស៊េរី ដែលបានប្រព្រឹត្តិដោយរដ្ឋាភិបាល និងគណបក្សកំពុងកាន់អំណាចដែលមានឥទ្ធិពល ធ្វើឲ្យចុះខ្សោយដល់មុខងារប្រជាធិបតេយ្យដ៏ត្រឹមត្រូវ និងលក្ខខណ្ឌដែលត្រូវការជាមុនរបស់វា។

(តមកពី ព្រឹត្តិបត្រ អ្នកឃ្លាំមើល លេខ ៤១)

## ២. សេរីភាពនៃការសម្តែងមតិរបស់សភាជាតិ

នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ សភាថ្មី បានស្បថចូលកាន់តំណែង និងបានអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់រដ្ឋសភាថ្មី។ តាមមាត្រា ៤៨ និងមាត្រា ៥៥ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជានេះ សមាជិករដ្ឋសភាជាតិត្រូវអង្គុយ និងរៀបចំជាក្រុម ហើយក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិច ១០ រូប ដែលមានប្រធានមួយរូប និងអនុប្រធានមួយរូប។ តំណាងរាស្ត្រមកពីគណបក្សនយោបាយណាដែលមានអាសនៈតិចជាង ១០ ត្រូវតែចូលរួមជាមួយនឹងក្រុមណាមួយ។ តំណាងរាស្ត្រមិនអាចបញ្ចេញមតិនៅក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាបានទេ លុះត្រាតែតំណាងរាស្ត្រជាសមាជិកនៃក្រុមណាមួយ និងដើម្បីបញ្ចេញមតិត្រូវសុំតាមរយៈប្រធានក្រុមរបស់ខ្លួន ហើយទទួលបានការអនុញ្ញាតពីប្រធានរដ្ឋសភាជាមុនសិន ទើបអាចនិយាយបាន។ បទបញ្ជាទាំងនេះ បានរារាំងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ចំនួន ៣ រូប ពីការបញ្ចេញមតិ នៅក្នុងរដ្ឋសភា ដោយសារពួកគេមិនបានចូលរួមក្នុងក្រុមណាមួយ ពីព្រោះពួកគេចង់រក្សាឯករាជភាពរបស់ពួកគេពីគណបក្សដទៃ។




បន្ថែមលើនេះទៀត ច្បាប់/លក្ខន្តិកៈសម្រាប់តំណាងរាស្ត្រ ត្រូវបានអនុម័តថ្មី ដែលស្រដៀងគ្នាទៅនឹងច្បាប់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (អ៊ុនតាក់) ឆ្នាំ១៩៩២ ដែលត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនោះ ដើម្បីឃាត់ខ្លួនអ្នករិះគន់រដ្ឋាភិបាល ដោយចោទប្រកាន់ពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍។ ការអនុម័តវិធានលក្ខន្តិកៈតំណាងរាស្ត្រថ្មីនេះ គឺ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលបានចែងថា តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុបាន សម្តែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។ ទោះបីជាយ៉ាងណា មាត្រា ៥ នៃច្បាប់ថ្មី បានដកចេញនូវការការពារទាំងនេះ គឺប្រសិនបើតំណាងរាស្ត្រណាមួយត្រូវបានរកឃើញថា បានរំលោភបំពានលើសេចក្តីថ្លៃថ្នូរបស់បុគ្គលឯកជន **ទំនៀមទម្លាប់សង្គម សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ** ដោយមិនចាំបាច់បញ្ជាក់ពីធម្មនុញ្ញភាព។ ពេលតំណាងរាស្ត្រ



ភ័យខ្លាចការចាប់ខ្លួន ពួកគេត្រូវបានកំណត់ព្រំដែនក្នុងការអនុវត្តកាតព្វកិច្ច របស់ពួកគេ ដើម្បីសម្តែងទស្សនៈ និងតស៊ូមតិសម្រាប់ផលប្រយោជន៍មណ្ឌលរបស់ពួកគេ។


សមាជិក នៃរដ្ឋសភា បើកសម័យប្រជុំរបស់ខ្លួន នៅវិមានរដ្ឋសភា កាលពីខែឧសភា ឆ្នាំ២០១០

## ៣. មុខងារនៃសភាជាតិ

រដ្ឋាភិបាលកម្ពុជា មានបំណងដើម្បីកំណត់មុខងារសេរីភាពប្រជាធិបតេយ្យ ដែលនៅក្នុងអំណាចទាំងបី របស់រាជរដ្ឋាភិបាល (នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ) អំណាចនីមួយៗ បំពេញមុខងារជា ព្រំដែន ឬរក្សាតុល្យភាពនៃអំណាចដទៃទៀត។ ទោះបីជាយ៉ាងណា នៅក្នុងការអនុវត្តជាក់ស្តែង អំណាចនីតិប្បញ្ញត្តិ និង តុលាការ មិនទាន់បានជោគជ័យនៅក្នុងការអនុវត្តជាព្រំដែនសម្រាប់កំណត់អំណាចនីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាល។ លទ្ធផលទាំងនេះ ចេញមកពីការត្រួតពិនិត្យលើអ្នកតំណាងរាស្ត្រ ដោយគណបក្សរបស់ពួកគេ និងមានយុទ្ធសាស្ត្រជាច្រើនទៀត ដើម្បីជាការរារាំងគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ដោយកំណត់ដែនកំណត់លើកិច្ចពិភាក្សាដេញដោលនៅក្នុងរដ្ឋសភា និងសម្លេងភាគច្រើន ដែលបានគ្រប់គ្រងដោយគណបក្សកាន់ អំណាចអំឡុងពេលអាណត្តិបច្ចុប្បន្ន។

ការជជែកពិភាក្សា នៅក្នុងរដ្ឋសភាបច្ចុប្បន្នបានកំណត់បន្ថែមទៀតដោយកត្តា ពីរ ៖ ពហិការរបស់គណបក្សប្រឆាំងក្នុងការចូលជាសមាជិក គណៈកម្មាធិការរដ្ឋសភា និងដែនកំណត់ដែលបានដាក់សម្រាប់កិច្ចពិភាក្សានៅពេលកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា ដោយគណបក្សកាន់អំណាច/រដ្ឋាភិបាល។ របាយការណ៍ឃ្លាំមើលសភា របស់ **ខុមហ្វ្រែល** បានលាតត្រដាងថា តំណាងរាស្ត្រ ២ រូប បាន លាលែងពីគណបក្សប្រជាជនកម្ពុជា ក្នុងឆ្នាំ ២០០៩ ប៉ុន្តែមូលហេតុនៃការលាឈប់របស់ពួកគេ មិនច្បាស់លាស់ទេ។

បន្ថែមពីនេះទៀត នៅក្នុងករណីខ្លះ រាជរដ្ឋាភិបាលកម្ពុជាបានស្នើថា ច្បាប់ពិតប្រាកដគួរតែ អនុម័តឲ្យបានឆាប់ ហើយមិនចាំបាច់ពិភាក្សាទេ។ សំណើនេះ គឺ តែងតែផ្ញើរដោយលិខិតទៅកាន់រដ្ឋសភា ដោយប្រធានគណៈកម្មការនៅពេលណែនាំច្បាប់។ ម្យ៉ាងវិញទៀត តំណាងរាស្ត្រជាច្រើនរូប បានផ្ញើសំណើទៅកាន់រាជរដ្ឋាភិបាលដើម្បីឲ្យឆ្លើយសំណួរ បានត្រឹមតែ ៣ ដង ក្នុងឆ្នាំ ២០០៩។ ២ ករណី ក្នុងចំណោមនោះ រាជរដ្ឋាភិបាល បានធ្វើតាមសំណើ ហើយបញ្ជូនតំណាងរបស់ខ្លួនទៅរដ្ឋសភា តែករណីមួយទៀត ដែលជាសំណើមួយ ធ្វើឡើងដោយតំណាងរាស្ត្រគណបក្សសមរង្ស៊ី (ឯកឧត្តម សុន ឆៃ) សម្រាប់ដេញដោលពីព័ត៌មានលម្អិតពាក់ពន្ធ័នឹងថវិការបស់រាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានត្រឹមតែតបជាលិខិតមកវិញថា ព័ត៌មានដែលបានស្នើអាចរកបាននៅលើគេហទំព័ររបស់ក្រសួង។

កិច្ចពិភាក្សា ដេញដោលជាច្រើននៅក្នុងរដ្ឋសភាពាក់ពន្ធ័នឹងសេចក្តីព្រាងច្បាប់ គឺកាន់តែត្រូវបានរឹតត្បិតពិសេសការសម្រេចចិត្តសំខាន់ៗ លើច្បាប់ដែលកំពុងត្រូវបានពិភាក្សា។ តួយ៉ាង **ច្បាប់ស្តីពី អស្សាមិករណ៍** ដែលចែងពីការដកហូតដីកម្មសិទ្ធិឯកជនរបស់ពលរដ្ឋ ត្រូវបានរដ្ឋសភាពិភាក្សា ហើយអនុម័តត្រឹមតែរយៈពេល **៦ ម៉ោងប៉ុណ្ណោះ។**

តទៅទំព័រ ៨

តមកពីទំព័រ ២

# ដំណោះស្រាយ និងភាពអត់ឱនខាងនយោបាយចំពោះទំនាស់ផលប្រយោជន៍តាមរយៈការបញ្ចេញមតិពិតជាសំខាន់

ដីការបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១០ បានផ្អាកការអនុវត្តបញ្ជាឲ្យបង្ខំ និងឃុំខ្លួនលោកជំទាវ មូរ សុខហួរ រង់ចាំការអនុវត្តប្រាក់សំណងជម្ងឺចិត្តជាមុនសិន។ ម្យ៉ាងតុលាការអាចអនុវត្តបង្ខំទារប្រាក់ តាមវិធាននៃនីតិវិធីរដ្ឋប្បវេណីសិន។

សេចក្ដីសម្រេចរបស់តុលាការតម្រូវឲ្យតំណាងរាស្ត្រស្រ្តី មូរ សុខហួរ បង់ប្រាក់ពិន័យ និងប្រាក់សំណងជំងឺចិត្តឲ្យដើមបណ្ដឹងរដ្ឋប្បវេណី [លោកនាយករដ្ឋមន្ត្រី] បានក្លាយជាវិវាទផ្លូវច្បាប់មួយផងដែរលើនីតិវិធីបង្ខំដល់រូបកាយ ប្រសិនបើអ្នកចាញ់ក្ដី [លោកជំទាវ មូរ សុខហួរ] មិនទទួលស្គាល់សេចក្ដីសម្រេចរបស់តុលាការ។ មាត្រា ៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានណែនាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយក្នុងការរឹបអូសចលនវត្ថុ ឬអចលនវត្ថុដើម្បីទារប្រាក់សំណង និងជំងឺចិត្តមុនពេលអនុវត្តការបង្ខំដល់រូបកាយ។



រូបភាព ៖ ខុមហ្វ្រែល (សវនាការ នៅសាលាដំបូងរាជធានីភ្នំពេញ)

តាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលបានចូលជាធរមានកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រឹមគន្ថីទី១ ៖ បទប្បញ្ញត្តិទូទៅ (ចាប់ពីមាត្រា ១ ដល់មាត្រា ១៨២) ក្នុងមាត្រា ២ បានធ្វើចំណាត់ថ្នាក់នៃ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើស។ ហើយតាមមាត្រា **៤៨** នៃក្រមដដែលនេះ បានក្ដោប បទលហុ ត្រឹមករណីពីរ គឺ ១- អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹងប្រាំមួយថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមទោសពិន័យជាប្រាក់ផងដែរ។ និង ២- បទល្មើសត្រូវផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។ មាត្រាទាំងនេះ បានទាញទម្លាក់ចំណាត់ថ្នាក់នៃបទបរិហាកេរ្តិ៍ ដែលជា«បទល្មើសមជ្ឈិម» តាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេស កម្ពុជា ក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ មកនៅត្រឹម «បទលហុ» វិញ ក៏ព្រោះតែ បទបរិហាកេរ្តិ៍ នេះមិនមានទោសដាក់ពន្ធនាគារ។

វិធានបង្ខំដល់រូបកាយ មិនគួរយកមកអនុវត្តលើតំណាងរាស្ត្រស្រ្តី ដែលរដ្ឋាភិបាលបានដាក់ចេញ នូវគោលនយោបាយលើកស្ទួយសិទ្ធិស្ត្រីទេ ម្យ៉ាងទៀត តំណាងរាស្ត្រ មូរ សុខហួរ ជាប់ទោសត្រឹម បទលហុ បើអនុវត្តនីតិវិធីបែបនេះអាចនឹងនាំឲ្យបាត់បង់សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងប៉ះពាល់ដល់សិទ្ធិ និងករណីយកិច្ចរបស់ពលរដ្ឋខ្មែរ ដើម្បីទៅបោះឆ្នោតផងដែរ។ មិនតែប៉ុណ្ណោះអាចធ្វើឲ្យមានការប៉ះពាល់ទៅដល់អ្នកបោះឆ្នោតរាប់ម៉ឺននាក់ ដែលបានបោះឆ្នោតឲ្យអ្នកតំណាងរាស្ត្រស្រ្តី មូរ សុខហួរ បាត់ បង់តំណាងរបស់ខ្លួន និងការបញ្ចេញឆន្ទៈរបស់ពួកគេក្លាយជាអត់ន័យ។

**គណៈកម្មាធិការប្រព្រឹត្តិកម្ម** បានផ្ដល់យោបល់ថា តុលាការអាចនឹងមានជម្រើសផ្សេងទៀត ដែល មិនប៉ះពាល់ដល់ការដាក់គុកបង្ខំរូបកាយលោកជំទាវ មូរ សុខហួរ។ ទីមួយ ៖ តុលាការអាចស្នើឲ្យមានការ កាត់ប្រាក់បៀវត្សរបស់លោកជំទាវ មូរ សុខហួរ ពីស្ថាប័នរដ្ឋសភា ជាស្ថាប័នដែលលោកជំទាវកំពុងបម្រើការ នៅក្នុងកម្រិតអប្បបរមាដើម្បីយកប្រាក់បៀវត្សដែលកាត់នោះទៅបង់ជាប្រាក់សំណងជំងឺចិត្ត សម្រាប់សម្ដេចនាយករដ្ឋមន្ត្រី និងប្រាក់ពិន័យសម្រាប់ជាថវិការដ្ឋ ។ ទីពីរ ៖ សូមស្នើសុំដល់សម្ដេចនាយករដ្ឋមន្ត្រី មេត្តាលើកលែងមិនយកប្រាក់ពិន័យ និងប្រាក់សំណងជំងឺចិត្តពីលោកជំទាវ មូរ សុខហួរ ដោយសារតែកិត្តិយសរបស់លោកត្រូវបានស្ដារ តាមរយៈការកាត់សេចក្ដីរបស់តុលាការបញ្ចប់រួចទៅហើយ។ ដូច្នេះការធ្វើបែបនេះ ដើម្បីចៀសផុតពីការដាក់គុកបង្ខំរូបកាយដល់លោកជំទាវមូរ សុខហួរ នៅក្នុងករណីមួយនេះ ហើយក៏ដើម្បីឲ្យទំនាស់នយោបាយរវាងភាគីទាំងពីរ បានបញ្ចប់ទៅដោយរលូនផងដែរ។



មានការព្រួយបារម្ភផងដែរអំពីការចោទប្រកាន់ទាក់ទិន **ករណីសកម្មជនគណបក្សសមរង្ស៊ី នៅខេត្តកំពង់ធំដែលត្រូវចោទពីបទភេរវកម្ម** ដែលនាំមកនូវបរិយាកាសភ័យខ្លាច និងបំបាក់ស្មារតីដល់សកម្មជនគណបក្សជំទាស់។ កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៤ នៅខេត្តកំពង់ធំ មានលេចឮពាក្យចចាមអារ៉ាមអំពីខ្លាក្រដាសប្រើម្នុលចាក់មនុស្ស ដែលនឹងធ្វើសកម្មភាពនៅក្នុងឃុំមួយចំនួន នៃស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។ ព័ត៌មាននេះ បានធ្វើឲ្យពលរដ្ឋមានការភ័យខ្លាចជាខ្លាំង តែសមត្ថកិច្ចមូលដ្ឋានមិនអាចបញ្ឈប់ឧបទ្ទវហេតុនេះបានទេ។ ក្រោយមកមានសកម្មជនគណបក្សសមរង្ស៊ី ពីររូប គឺ [១]លោក **គឹម ហុង** (ជំទប់ ទី២ ឃុំក្រយា) និង [២]លោក **អ៊ុក ថន** (សមាជិកក្រុមប្រឹក្សាស្រុក ប្រាសាទបល្ល័ង្ក) និងប្រជាពលរដ្ឋពីររូប ទៀត មាន [៣]លោក.**កុយ គឿន** និង[៤]លោក.**អ្វូត ធុន** បាននាំយកស្នាមមេដៃរបស់ប្រជាពលរដ្ឋទៅដាក់នៅក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការដោះស្រាយដោយចាត់ឲ្យមានសន្តិសុខ យាមកាមទើបសភាពការណ៍ស្ងប់ស្ងាត់ទៅវិញ។

នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១០ ចៅក្រមស៊ើបអង្កេតនៃសាលាដំបូងខេត្តកំពង់ធំ លោក **សេង លាង** បានចេញដីកាបង្គាប់អ្នកពាក់ពន្ធ័ចំនួន៤ **រូប** ឲ្យចូលខ្លួនទៅតុលាការខេត្ត ដើម្បីឆ្លើយបំភ្លឺដំណើររឿងអំពើភេរវកម្មកាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៤ កើតនៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ដោយក្នុងនោះរួមមាន [១]លោក **គឹម ហុង** [២]លោក **អ៊ុក ថន** [៣]លោក **កុយ គឿន** និង[៥]លោក **ចោម ជាវ** ដែលអ្នកទាំងនោះសុទ្ធតែត្រូវបានចោទពីបទភេរវកម្ម ដោយសំអាងលើបទ ល្មើសដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្ដីពី **ការផ្ដន្ទាទោសអំពើភេរវកម្ម ឆ្នាំ១៩៩២** ។

តាមមាត្រា ២ នៃច្បាប់ស្ដីពី ការផ្ដន្ទាទោសអំពើភេរវកម្ម ឆ្នាំ១៩៩២ ដែលព្រះរាជអាជ្ញាបានសំដៅដល់បានប្បញ្ញត្តិទុកថា ៖ ជនណាចាប់ពង្រាត់មនុស្ស ឬបង្ខាំងមនុស្សដោយខុសច្បាប់ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារយកប្រាក់សងសឹក ធ្វើចំណាប់ខ្មាំង យកទៅលក់ និងជនណាដែលប្រព្រឹត្តិអំពើភេរវកម្មផ្សេងៗទៀត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ដល់ ២០ឆ្នាំ។ យោងតាមមាត្រា ១ នៃច្បាប់ដដែលខាងលើ បានផ្ដល់សញ្ញាណអំពី អំពើភេរវកម្មថា ជាអំពើហិង្សាទាំងឡាយ ដែលប្រព្រឹត្តិដោយជនមួយនាក់ ឬជនមួយក្រុម ឬ ច្រើនក្រុម បង្កើតភាពភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឲ្យជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្ដាប់ធ្នាប់ **និងសន្តិសុខសាធារណៈ និងឲ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ។**

តាមការបង្ហាញរបស់តុលាការ ជនត្រូវចោទ មានបន្ទុកត្រឹមបង្កើតភាពភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជនដែលជាការសន្និដ្ឋានផ្អែកតាមរបាយការណ៍មួយដ៏គួរឲ្យសង្ស័យ ព្រោះផ្អែកតាមអង្គហេតុដែលបានផ្ដល់ជូនខាងលើជនត្រូវចោទទាំងបួន [១]លោក **គឹម ហុង** [២]លោក **អ៊ុក ថន** [៣]លោក **កុយ គឿន** និង[៥]លោក **ចោម ជាវ** សុទ្ធតែត្រូវប្រែសភាពជាសាក្សី ទៅជាជនត្រូវចោទពីបទភេរវកម្ម ជំនួស [៤]លោក **អ្វូត ធុន** ដែលហាក់បង្ហាញថា មានភាពស្រពិចស្រពិលពីធាតុល្មើស និងបទចោទជាខ្លាំង។ តាមការបកស្រាយច្បាប់ ក្នុងបទភេរវកម្ម ជនល្មើស ត្រូវតែបង្គ្រប់ដោយធាតុផ្សំសំខាន់រួមទាំង ៖ **គោលដៅធ្វើឲ្យជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្ដាប់ធ្នាប់** បូកផ្សំនិង **សន្តិសុខសាធារណៈ** បន្ថែមនិង **ប៉ះពាល់ដល់ស្ថិរភាពនយោបាយ** មិនមែនត្រឹមតែធាតុ បង្កើតភាពភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន មួយអាចគ្រប់សម្រាប់ បទចោទដ៏ធំធេងបែបនេះទេ។ ភេរវកម្ម ជាបទល្មើសអន្តរជាតិដែលមានចែងក្នុងអនុសញ្ញា និងពិធីសារអន្តរជាតិរបស់អង្គការសហប្រជាជាតិ និងច្បាប់ស្ដីពី ការប្រឆាំងនឹងភេរវកម្ម ហើយទាមទារឲ្យមានធាតុផ្សំ រចនាសម្ព័ន្ធ និងបញ្ជីភេរវកម្មអន្តរជាតិផងដែរ មិនមែនត្រឹមតែការសន្និដ្ឋានមួយ ដែលគ្មានមូលដ្ឋានច្បាស់លាស់បែបនេះទេ។

បើសិនមានសកម្មភាពចាប់អ្នកតំណាងរាស្ត្រចូលពន្ធនាគារ បង្ហាញថា ស្ថាប័នកំពូលៗរបស់រដ្ឋ បាននឹងកំពុងធ្វើឲ្យឥទ្ធិពល និងអំណាចរបស់តំណាងរាស្ត្រកាន់តែធ្លាក់ចុះ ដោយសារតែការបញ្ចេញមតិ ដែលកើតឡើងដោយអ្នកនយោបាយជាថ្នាក់ដឹកនាំគណបក្សជំទាស់។ ម្យ៉ាងវិញទៀត ករណីនេះក៏បានប៉ះពាល់ដល់រដ្ឋធម្មនុញ្ញដែលស្ថាប័នសភាខ្លួនឯងដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រ ដោយសារត្រឹមតែករណីនៃការបញ្ចេញមតិ ឬការឆ្លើយឆ្លង

សម្ដីគ្នា។

ប្រពន្ធ័តុលាការ និងយុត្តិធម៌នៅកម្ពុជា គឺកំពុងស្ថិតនៅក្នុងដំណើរការនៃការធ្វើកំណែទម្រង់ នៅក្នុងស្ថានការបែបនេះ មតិជាតិ និងអន្តរជាតិ មិនទាន់ផ្ដល់ជំនឿទុកចិត្តនៅឡើយទេ។ «សហភាពអន្តរសភា» ដែលរិះគន់ដំណើរការដកអភ័យសិទ្ធិសភាអ្នកតំណាងរាស្ត្រ មូរ សុខហួរ ថា «មិនស្របតាមច្បាប់» ហើយថ្មីៗនេះ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោកស្រី **ណាវី ភីល័យ** (Navi Pillay) បានហៅ ករណីលោកស្រី មូរ សុខហួរ ដែលតុលាការកម្ពុជាកាត់ក្ដីឲ្យលោកស្រីចាញ់ លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ជាការប្រកាសអាសន្នចំពោះការធ្លាក់ចុះសិទ្ធិសេរីភាពនៅប្រទេសកម្ពុជា។

ទោះបីជាយ៉ាងណា នៅថ្ងៃទី **២៩ ខែកក្កដា ឆ្នាំ២០១០** គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា បានសម្រេចកាត់ប្រាក់ខែរបស់ លោកជំទាវ មូរ សុខហួរ តំណាងរាស្ត្រគណបក្សប្រឆាំង ដែលរងសេចក្ដីសម្រេចរបស់តុលាការពីបទ «បរិហារកេរ្តិ៍» លោកនាយករដ្ឋមន្ត្រី ចំនួន ៨.០០០ ០០០ (ប្រាំបីលាន) រៀល ក្នុងរយៈពេល ២ ខែ (ចាប់ពីខែកក្កដា ឆ្នាំ២០១០) តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់បង់សំណងជម្ងឺចិត្តដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ តាមរូបភាពពិន័យរដ្ឋបាល ដោយកាត់ប្រាក់បៀវត្សត្រឹម ៨ លាន រៀល បែបនេះ អាចដោះស្រាយឲ្យជ្រះស្រឡះត្រឹមកំហុសរដ្ឋប្បវេណីប៉ុណ្ណោះ ខណៈដែលលោកជំទាវ មូរ សុខហួរ មិនពេញចិត្តនឹងបង់ប្រាក់តាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការនៃរដ្ឋសភា។ ប្រសិនបើព្រះរាជអាជ្ញាមានបំណងធ្វើបាប តំណាងរាស្ត្រគណបក្សប្រឆាំង ដោយសំអាងលេសលោក ជំទាវ មូរ សុខហួរ មិនសុខចិត្តបង់ប្រាក់ពិន័យ វិធានបង្ខំរូបកាយនៅតែស្ថិតក្នុងស្រមោលអកុសលនៃកំហុសព្រហ្មទណ្ឌបទល្មើសលហុ [បរិហារកេរ្តិ៍] ដែលតម្រូវឲ្យលោកជំទាវបង់ប្រាក់ពិន័យចំនួន **៨,៥ លាន រៀល** ទៅឲ្យរតនាគារជាដែល ឬស្មើនឹងទោសជាប់ពន្ធនាគារចន្លោះពី ៣ ខែ ទៅ ៦ ខែ ស្របតាមមាត្រា ៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជម្រើសល្អ គឺការអត់ឱន ឬការសម្រុះសម្រួលខាងនយោបាយ ដើម្បីលើកស្ទួយសេរីភាព និងប្រជាធិបតេយ្យ។ ប៉ុន្តែមានប្រតិកម្មលើកឡើងថា ការបន្តអត់ឱន និងសម្រុះសម្រួលនៃអ្នកនយោបាយ អាចជះឥទ្ធិពលដល់នីតិរដ្ឋ និងប្រពន្ធ័យុត្តិធម៌នៅកម្ពុជាមែនឬទេ? ប្រទេសកម្ពុជា ធ្លាប់អនុវត្តការសម្រុះសម្រួលនយោបាយ តាំងពីឆ្នាំ១៩៩៣។ នៅឆ្នាំ ១៩៩៨ អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ធ្លាប់បានប្រទានការលើកលែងទោសដល់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលតុលាការកាត់ទោស ព្រះអង្គឲ្យជាប់ពន្ធនាគារ ៣០ ឆ្នាំ។ កាលពី ខែកុម្ភៈ ឆ្នាំ ២០០៦ ព្រះមហាក្សត្រ នរោត្តម សីហមុនី ធ្លាប់ បានសម្របសម្រួលជម្លោះនយោបាយបែបនេះ ដោយទ្រង់ប្រទានការលើកលែងទោសដល់ឯកឧត្តម សម រង្ស៊ី ដែលត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារ ១៨ ខែ។

រាជរដ្ឋាភិបាលកម្ពុជា បានខិតខំការពារកិច្ចសម្រុះសម្រួល និងស្ថិរភាពជាតិ ដោយធ្លាប់បាន ព្រមានដំណើរការនៃការចោទប្រកាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅលើអតីតមេដឹកនាំខ្មែរក្រហម ដែលទទួលខុសត្រូវឧក្រិដ្ឋកម្ម ឆ្នាំ១៩៧៥-១៩៧៩ ថា មិនអាចរាលដាលបន្ថែមលើសពី ករណី ៥ នាក់ ( [១].លោក កាំង ហ្គេចអៀវ [២]. លោក ខៀវ សំផន [៣].លោក នួន ជា [៤].លោក អៀង សារី និង[៥]លោកស្រី អៀង ធីរិទ្ធ) នេះទេ។ រាជរដ្ឋាភិបាលជឿថា វាអាចបង្កឲ្យមានសង្គ្រាម និងអស្ថិរភាព។ បើនិយាយអំពីកម្រិត នៃការចោទប្រកាន់បទល្មើស រវាងឧក្រិដ្ឋកម្មរបស់អ្នកទទួលខុសត្រូវខ្មែរក្រហម គឺធ្ងន់ធ្ងរខ្លាំងណាស់បើប្រៀប ធៀបជាមួយនឹងការចោទប្រកាន់ទៅអ្នកនយោបាយគណបក្សប្រឆាំង។ រាជរដ្ឋាភិបាលក៏កុំបំភ្លេចថាគណបក្ស នយោបាយ និងអ្នកនយោបាយបានចូលរួមចំណែកឲ្យមានស្ថិរភាព និងការអភិវឌ្ឍប្រជាធិបតេយ្យ។

ដូច្នេះ រដ្ឋាភិបាល និងអ្នកដឹកនាំនយោបាយខ្មែរមកពីគ្រប់និន្នាការនយោបាយ ឬគណបក្សនយោ- បាយ គួរតែគិតគូរយកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់ប្រទេសជាតិជាធំ និងការលើកស្ទួយប្រជាធិបតេយ្យ តាមរយៈការដោះស្រាយបញ្ហាទំនាស់នយោបាយដោយសន្តិវិធី និងការអត់ឱននយោបាយ៕



តមកពីទំព័រ ៤ ▸

# របាយការណ៍ឆ្នាំ ២០០៩ ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា

កិច្ចពិភាក្សា ដេញដោលជាច្រើននៅក្នុងរដ្ឋសភាពាក់ពន្ធ័នឹងសេចក្ដីព្រាងច្បាប់ គឺកាន់តែត្រូវបានរឹតត្បិតពិសេសការសម្រេចចិត្តសំខាន់ៗ លើច្បាប់ដែលកំពុងត្រូវបានពិភាក្សា។ តួយ៉ាង **ច្បាប់ស្ដីពី អស្សាមិករណ៍** ដែលចែងពីការដកហូតដីកម្មសិទ្ធិឯកជនរបស់ពលរដ្ឋ ត្រូវបានរដ្ឋសភាពិភាក្សា ហើយអនុម័តត្រឹមតែរយៈពេល **៦ ម៉ោង** ប៉ុណ្ណោះ។ ›››

**ច្បាប់ស្ដីពី ការធ្វើបាតុកម្មដោយសន្តិវិធី** ដែលចំណុះទៅដោយអនុប្រយោគធ្ងន់ធ្ងរជាច្រើន ដែលអាចរឹតបន្តឹងដល់សិទ្ធិសេរីភាពបញ្ចេញមតិ ត្រូវបានរដ្ឋសភាពិភាក្សាអស់រយៈពេល **៧ ម៉ោង។ ក្រមព្រហ្មទណ្ឌ** សម្រាប់ពលរដ្ឋកម្ពុជា ដែលបានរង់ចាំអស់ជាច្រើនឆ្នាំ ត្រូវបានពិភាក្សាអស់រយៈពេលត្រឹមតែ **១៣ ម៉ោង** ទោះបីក្រមនេះមានអនុប្រយោគដែលមានភាពប្រទាំងប្រទើសជាច្រើន ដែលគួរត្រូវពិភាក្សាឲ្យបានច្រើនទាក់ទងនឹងបទបរិហារកេរ្តិ៍។

ចំពោះបញ្ហាយេនឌ័រ ស្ត្រីបានដើរតួនាទីយ៉ាងល្អជាអ្នកអត្ថាធិប្បាយនៅក្នុងសភា ដោយមានតំណាងរាស្ត្រស្ត្រី ១១ រូប នៃចំនួនសរុប ២៦រូប ដែលបាននិយាយក្នុងអំឡុងពេលប្រជុំពេញអង្គនៃរដ្ឋសភា (ស្មើនឹង ៤២%)។ តួលេខនេះ មានកម្រិតប្រសើរជាង បើប្រៀបនឹងអ្នកតំណាងរាស្ត្របុរសដែលមានចំនួន ៣៤ រូប នៃអ្នកតំណាងរាស្ត្រ ៩៧ រូប បាននិយាយអំឡុងពេលប្រជុំពេញអង្គ នៃរដ្ឋសភា (ស្មើនឹង៣៥%)។ ទោះបីជាយ៉ាងណាតំណាងរាស្ត្រ មានចំនួនត្រឹមតែ ២១% នៃចំនួនតំណាងរាស្ត្រសរុប ដែលមិនបានដល់គោលដៅក្នុងការ ឲ្យមានតំណាងរាស្ត្រស្ត្រី ៣០% ហើយកាន់តែមានគម្លាតឆ្ងាយពីសមភាពយេនឌ័រ។

## ៤. សេរីភាពនៃសារព័ត៌មាន

ការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយ សម្រាប់គណបក្សនយោបាយធំៗ និងការបង្ហាញដោយមិនលម្អៀងនៃព្រឹត្តិការណ៍ជាច្រើននៅក្នុងប្រទេស គឺជាផ្នែកសំខាន់មួយនៃការប្រព្រឹត្តិទៅនៃប្រពន្ធ័ប្រជាធិបតេយ្យ ដែលអ្នកបោះឆ្នោតអាចធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានអំពីការបំពេញមុខងារនៃគណបក្សជាច្រើន ព្រមទាំងស្ថានភាពទូទៅនានានៅក្នុងប្រទេស។

ក្នុងឆ្នាំ ២០០៩ និងបន្តពីឆ្នាំមុនៗ ប្រពន្ធ័ផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងប្រពន្ធ័ផ្សព្វផ្សាយដែលមានកាសែត វិទ្យុ និងទូរទស្សន៍ នៅតែបន្តមានលក្ខណៈជារចនាសម្ព័ន្ធ ជារបៀបដែលដាក់គណបក្សប្រឆាំងនៅក្នុងស្ថានភាពងាយរងគ្រោះធ្ងន់ធ្ងរ ពីការរិះគន់ទម្លាក់ប្រជាប្រិយភាព ការរឹតត្បិតព័ត៌មាន និងការបញ្ចេញមតិ និងការបញ្ចេញទស្សនៈទៅកាន់ពលរដ្ឋកម្ពុជា។

មានអ្នកសារព័ត៌មាន ៣១ រូប ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ២០០៩ កើនឡើងពីរដង បើធៀបទៅនឹងឆ្នាំ ២០០៨ ដែលមានត្រឹមតែ អ្នកសារព័ត៌មាន ១៤ រូប ដែលត្រូវបានចាប់ខ្លួន ដោយអាជ្ញាធរ។ អ្នកសារព័ត៌មាន



ក្រុមអ្នកយកព័ត៌មាន តាមដានសម័យប្រជុំនៃរដ្ឋសភាកម្ពុជា

២ រូប ក្នុងចំណោម ៣១ រូប ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត។

ប្រពន្ធ័ផ្សព្វផ្សាយតាមវិទ្យុ គឺជាឧបករណ៍ដ៏មានប្រសិទ្ធិភាពមួយ ដើម្បីឲ្យបានដល់ពលរដ្ឋនៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនរស់នៅតំបន់ជន បទដែលពុំសូវមានទូរទស្សន៍ និងសូម្បីតែកាសែតក៏មិនអាចចែកផ្សាយទៅដល់។ ទោះបីជាយ៉ាងនេះ ការប្រើប្រាស់វិទ្យុ គឺនៅមានកម្រិតជាខ្លាំងចំពោះ គណបក្សប្រឆាំង ដែលអាចប្រើប្រាស់ត្រឹមតែពីរ ឬបី ប៉ុស្តិ៍វិទ្យុ ដែលមានលទ្ធភាពផ្សព្វផ្សាយទៅដល់ខេត្តមួយចំនួន។ នៅក្នុងទីក្រុង គណបក្សសមរង្ស៊ី អាចគ្រប់គ្រងបាន ២ ស្ថានីយ៍វិទ្យុ ខណៈដែលមានស្ថានីយ៍វិទ្យុឯករាជ្យចំនួន ២ ដែលអាចលក់ម៉ោងផ្សាយឲ្យគណបក្សប្រឆាំង។ គណបក្សហ៊្វុនស៊ិនប៉ិច កាន់កាប់ស្ថានីយ៍វិទ្យុ ២ ប៉ុន្តែ បច្ចុប្បន្នវិទ្យុទាំងនោះ បានក្លាយជាផ្នែកមួយនៃសម្ព័ន្ធភាពរបស់គណបក្សកាន់អំណាចក្នុងរដ្ឋាភិបាល។ ផ្ទុយទៅវិញ គណបក្សប្រជាជនកម្ពុជា អាចប្រើប្រាស់យ៉ាងហោចណាស់ ៣៩ ប៉ុស្តិ៍វិទ្យុ រាប់បញ្ចូលទាំងបណ្ដាញវិទ្យុរដ្ឋ និងឯកជនដែលអាចផ្សាយទៅដល់ទូទាំងប្រទេស។

នៅក្នុងឆ្នាំ ២០០៩ ក្រសួងព័ត៌មានបានប្រកាស ជូនដំណឹងថា ក្រសួងមិនមានអាជ្ញាប័ណ្ណវិទ្យុសម្រាប់លក់ទៀតទេ មានន័យថា គណបក្សប្រឆាំងនឹងមាន ផលវិបាកជាខ្លាំង ដើម្បីទទួលបានការប្រើប្រាស់ប៉ុស្តិ៍វិទ្យុបន្ថែមទៀត លើស្ថានីយ៍វិទ្យុដែលពួកគេអាចប្រើប្រាស់ បាននាពេលបច្ចុប្បន្ន។

ប្រពន្ធ័ផ្សព្វផ្សាយតាមទូរទស្សន៍ គឺគ្របសង្កត់យ៉ាងលើសលប់ដោយគណបក្សកាន់អំណាច ឬ សម្ព័ន្ធមិត្តរបស់ខ្លួន នៅក្នុងសហគមន៍ពាណិជ្ជកម្ម។ គណបក្សប្រឆាំងមិនអាចប្រើប្រាស់ការផ្សព្វផ្សាយតាមទូរទស្សន៍ឡើយ លើកលែងតែនៅក្នុងកម្មវិធីទូរទស្សន៍តែមួយគត់ គឺកម្មវិធីសមធម៌ របស់ទូរទស្សន៍ជាតិកម្ពុជាដែលបាន ឧបត្ថម្ភដោយ



តំណាងរាស្ត្រគណបក្សសមរង្ស៊ី បង្ហាញទស្សនៈតាមកម្មវិធីទូរទស្សន៍សមធម៌


ក្រុមការងារខុមហ្វ្រែល អង្កេតមើលរដ្ឋាភិបាលតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ

កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ដែលសមាជិកសភាគណបក្សប្រឆាំង ពេលខ្លះត្រូវបាន សម្ភាសន៍ពាក់ពន្ធ័នឹងការជជែកវែកញែកស្តីពីសេចក្តីព្រាងច្បាប់នៅក្នុងរដ្ឋសភា។ ការអង្កេតរបស់ខុមហ្វ្រែល លើកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០០៩ បានរកឃើញថា គណបក្សសមរង្ស៊ី និង តំណាងរាស្ត្ររបស់ខ្លួន បានបង្ហាញ នៅក្នុងកម្មវិធីនេះ ច្រើនជាងគណបក្សនយោបាយដទៃទៀត ដោយបានបង្ហាញខ្លួន ៤៨ ដង។ គណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្ររបស់ខ្លួនបានបង្ហាញខ្លួន ១៦ ដង គណបក្សសិទ្ធិមនុស្ស និងតំណាងរាស្ត្ររបស់ខ្លួន បានបង្ហាញខ្លួន ១៨ ដង គណបក្សហ្វ៊ុនស៊ិនប៉ិច និង គណបក្សជាតិនិយម (អតីតគណបក្សនរោត្តមរណឫទ្ធិ) រួមគ្នាបានបង្ហាញសរុប ១២ ដង។

គ្រប់ស្ថានីយ៍ទូរទស្សន៍ គឺបានកាន់កាប់ដោយរាជរដ្ឋាភិបាលផ្ទាល់ ដោយចំរុះរវាងរាជរដ្ឋាភិបាល និងឯកជន ដោយសមាជិកនៃគណបក្សកាន់អំណាច ឬ ដោយមហាសេដ្ឋីដែលជាសម្ពន្ធ័នឹងគណបក្សកាន់អំណាច ឬ ក្រុមគ្រួសារនៃសមាជិករាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា។ ជាលទ្ធផល គេសង្កេតឃើញថា នាទីព័ត៌មាន ដែលបានផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍កម្ពុជាជាទៀងទាត់ ផ្សព្វផ្សាយសន្និសីទ ដែលបានបង្ហាញ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា និយាយនៅពេលប្រជុំ ចំណែកជម្លោះដីធ្លី ដែលមានជារឿយៗ គេមិនអាចប្រទះឃើញព័ត៌មានទាំងនេះលើកញ្ចក់ទូរទស្សន៍ទាល់តែសោះ។ ប្រព័ន្ធផ្សព្វផ្សាយតាមទូរទស្សន៍ ក៏ជួយលើកស្ទួយគណបក្សកាន់អំណាចផងដែរ ដោយការបង្ហាញរូបភាព និងសកម្មភាពសមាជិករាជរដ្ឋាភិបាល និងគណបក្សកាន់អំណាចចែកអំណោយទៅដល់ជនក្រីក្រ ឬទៅដល់ទាហាននៅប្រាសាទព្រះវិហារ។ សុន្ទរកថា របស់លោកនាយករដ្ឋមន្ត្រី គឺតែងតែផ្សព្វផ្សាយយ៉ាងយូរ និងស្រូបម៉ោងផ្សព្វផ្សាយយ៉ាងច្រើន ដែលបង្ហាញពីការពង្រឹងវិសាលភាព គ្របដណ្តប់របស់នាយករដ្ឋមន្ត្រី ទៅលើទិដ្ឋភាពនយោបាយទូទៅ នៅកម្ពុជា។ បណ្តាញទូរទស្សន៍កម្ពុជា ស៊ីធីអ៊ិន និងជាពិសេសទូរទស្សន៍បាយ័ន ក៏ត្រូវបានប្រើប្រាស់ដោយគណបក្សកាន់អំណាចផងដែរ ដើម្បីបង្ខូចកិត្យានុភាព និងរិះគន់គណបក្សប្រឆាំង និងអង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលតាម រយៈកម្មវិធីជជែកពិភាក្សាដែលកន្លងមកគណបក្សប្រឆាំង ឬអង្គការមិនមែន រដ្ឋាភិបាល មិនមានឱកាសដើម្បីឆ្លើយតបចំពោះការរិះគន់ទាំងនេះ តាមទូរទស្សន៍នោះទេ។

## ៥. អនុសាសន៍

ខុមហ្វ្រែល សូមផ្តល់អនុសាសន៍អាទិភាពសម្រាប់កំណែទម្រង់បរិយាកាសឲ្យប្រសើរជាងនេះ ៖

» គួរមានច្បាប់ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយ



ដែលរៀបរាប់ពីការចំណាយ និង/ឬ ហាមប្រាមការប្រើប្រាស់ថវិកាជាតិនៅក្នុងអត្ថប្រយោជន៍ គណបក្សនយោបាយ ដើម្បីបង្កើនតម្លាភាពនៃថវិកាដែលបានប្រើប្រាស់នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

» ពង្រឹងក្របខណ្ឌច្បាប់ សម្រាប់ប្រពន្ធ័ផ្សព្វផ្សាយ ដើម្បីធានាការអនុវត្តតាមគោលការណ៍ស្មើភាព និងសមធម៌ និងតុល្យភាពនៃព័ត៌មាន សម្រាប់ការបោះឆ្នោតប្រកួតប្រជែង នៃគ្រប់គណបក្សនយោបាយទាំងអស់។

» ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រី កូតា អប្បបរមា ៣០% គួរតែទទួលយកដោយស្ថាប័នរដ្ឋាភិបាលទាំងអស់ និងគួរតែរាប់បញ្ចូលបទបញ្ជាសមាជិកភាពនៃគ្រប់គណបក្សនយោបាយទាំងអស់ ដែលត្រូវតែសម្រេចនៅឆ្នាំបន្ទាប់។

» កំណែទម្រង់ប្រពន្ធ័បោះឆ្នោត ដោយអនុវត្តប្រពន្ធ័ចំរុះ ដែលអនុញ្ញាតឲ្យបេក្ខជនឯករាជ្យ និង/ឬ បេក្ខ-ជនឯកជនព្រមទាំងគណបក្សនយោបាយ (ដែលប្រើប្រាស់បញ្ជីឈ្មោះគណបក្ស) ដើម្បីប្រជែងយកតំណែងនៅគ្រប់កម្រិតនៃរដ្ឋាភិបាល។

» រដ្ឋាភិបាលគួរតែផ្លាស់ប្តូរប្រពន្ធ័នៃការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី ដោយ ឲ្យពលរដ្ឋកម្ពុជា អាចបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាទាំងនោះ ប្រសើរជាងផ្តល់ឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបោះឆ្នោតជ្រើសរើស។

» ធ្វើឲ្យប្រសើរឡើងនូវមុខងារនៃរដ្ឋសភា ត្រូវកំណែទម្រង់បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈនៃរដ្ឋសភា ដើម្បីអនុញ្ញាតឲ្យគ្រប់គណបក្សអាចនិយាយបានអំឡុងប្រជុំពេញអង្គនៃរដ្ឋសភា និងដកចេញនូវអនុប្រយោគមួយចំនួន ដែលដាក់ទោសតំណាងរាស្ត្រ សម្រាប់ការបញ្ចេញទស្សនៈមតិ ក្នុងពេលបំពេញមុខងាររបស់ពួកគេជាតំណាងរាស្ត្រ។

» ខុមហ្វ្រែល សូមស្នើដល់រាជរដ្ឋាភិបាលធានាឲ្យមានការបញ្ចេញមតិយោបល់កាន់តែទូលំទូលាយ ចំពោះអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស ពលរដ្ឋតូចតាច និងតំណាងរាស្ត្រគណបក្សប្រឆាំង និងពិចារណាលើការបញ្ឈប់ការចោទប្រកាន់ពីបទ បរិហារកេរ្តិ៍ និងបទចោទប្រកាន់ដទៃទៀត ដើម្បីធានាថា ពួកគេអាចចូលរួមបញ្ចេញមតិ យោបល់រិះគន់ ដោយសេរីក្នុងន័យស្ថាបនា និងជជែកដេញដោលពាក់ពន្ធ័នឹងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល និងគណបក្សកាន់អំណាច ដែលទាំងនេះ ជាសិទ្ធិ និងករណីយកិច្ចរបស់ពួកគេជាពលរដ្ឋ៕

**ការផ្សាយសម្លេងសង្គមស៊ីវិល**

»»»ផ្សាយផ្ទាល់ ៖ **រាល់ថ្ងៃច័ន្ទ ដល់ ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧. ៣០ នាទី ដល់ ម៉ោង ៨.៣០ នាទីព្រឹក**

»»»តាមរយៈ ៖ **វិទ្យុ** FM 105 MHz (**ភ្នំពេញ**), FM 90 MHz (**ភ្នំពេញ**),

»»»ផ្សាយបន្តទៅតាមបណ្តាខេត្ត ៖ FM 90.25 MHz (**បាត់ដំបង**),
FM 88.5 MHz (**កំពង់ធំ**)

»»»ចាក់ផ្សាយនៅវិទ្យុអង្គរដ្ឋា ខេត្ត **សៀមរាប** ពីម៉ោង១២:៣០ ដល់ ១៣:០០ FM 95.5 MHz

»»»ចូលរួមបញ្ចេញមតិយោបល់ ៖ 023 88 57 45, 016 54 43 98, 012 43 34 37

»»»ផ្ញើសារជាអក្សរ (SMS) ៖ 017 91 92 80

»»»អ៊ីម៉ែល ៖ comfrel@online.com.kh & »»»គេហទំព័រ ៖ www.comfrel.org

# មូលនិធិគណបក្សនយោបាយ និងអំពើពុករលួយរបស់គណបក្សនយោបាយ នៅអាស៊ីខាងកើត

## ករណីសិក្សានៅប្រទេស ជប៉ុន កូរ៉េខាងត្បូង និងតៃវ៉ាន់

អត្ថបទស្រាវជ្រាវ និងប្រែសម្រួលដោយ ៖ តែម ផារ័ត្ន
(តមកពី ព្រឹត្តិបត្រ អ្នកឃ្លាំមើល លេខ ៤១)



ការឃោសនាបោះឆ្នោត ក្នុងឆ្នាំ២០០៥


សភាប្រទេសជប៉ុនបើកប្រជុំ ក្នុងឆ្នាំ២០០៥



រូបភាពបេក្ខជនឃោសនាបោះឆ្នោត ក្នុងឆ្នាំ២០១០

### ៣- ការដាក់ឲ្យអនុវត្តច្បាប់ស្តីពីមូលនិធិគណបក្សនយោបាយ

ចំនួនថវិកាពិតប្រាកដ ដែលបានលើកឡើង មានការលំបាកក្នុងការធ្វើនិទស្សន៍។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋមានច្បាប់ស្តីពីរបាយការណ៍លើមូលនិធិគណបក្សនយោបាយ ជាពិសេសសមាជិកនីមួយៗ នៃគណបក្សនយោបាយ ដែលមានភាពមិនជាក់លាក់នៅក្នុងរបាយការណ៍។ នៅដើមទសវត្សឆ្នាំ ១៩៥០ ត្រូវបានគេធ្វើការប៉ាន់ប្រមាណថា បេក្ខជនម្នាក់ៗចាំបាច់ត្រូវចំណាយរវាងពី ៥ ទៅ ៦ ដងច្រើនជាងអ្វីដែលបានអនុញ្ញាតដោយច្បាប់ (Ike 1957:200)។ មានក្រុមជាច្រើន ប្រសិនបើគេបានធ្វើការកត់សម្គាល់អត្តសញ្ញាណ ត្រូវតម្រូវឲ្យធ្វើរបាយការណ៍ពីចំណូលរបស់ខ្លួន ប៉ុន្តែពេលខ្លះ គេជ្រើសយក ដោយធ្វើការបែងចែកថវិកាដែលទទួលបានជាលក្ខណៈបុគ្គលនៅក្នុងក្រុម ឬបក្សពួករបស់គេ។ ពួកគេនឹងជ្រើសរើស ធ្វើសេចក្តីរាយការណ៍ ទៅតាមចំនួនតិច ឬច្រើនតាមដែល សាធារណៈរំពឹងថាមានការប្រែប្រួលទៅលើមុខងារជាក់លាក់ ដែលគេចង់ផ្តោតការចាប់អារម្មណ៍ ឬផ្តល់តម្លៃទាប។ ជំនួយឧបត្ថម្ភដល់ស្ថាប័ននយោបាយ គឺអាចកាត់ពន្ធបាន ហើយចំពោះសាជីវកម្មខ្នាតធំ ដែលផ្តល់ជំនួយច្រើននោះគេចាប់អារម្មណ៍ធ្វើបែបនេះ។ ទោះ បីជាយ៉ាងណា ស្ថាប័នតូចតាចមិនសូវមានភាពច្បាស់លាស់ក្នុងការពិនិត្យពិច័យនោះទេ ហើយករណីខ្លះក្រុម ហ៊ុនដែលឧបត្ថម្ភថវិកាទាំងនោះ រំពឹងថាការបកស្រាយវិធាននានារបស់រដ្ឋនឹងប្រតិបត្តិយ៉ាងប្រសើរ ផ្តល់ប្រយោជន៍ដល់ពួកគេ ប្រសិនបើពួកគេរក្សាការសម្ងាត់ក្នុងការផ្តល់ថវិកាឧបត្ថម្ភជាជាងការផ្សព្វផ្សាយជាសាធារណៈ ហើយបើមានការផ្សព្វផ្សាយជាសាធារណៈនឹងធ្វើឲ្យប៉ះពាល់ដល់ថៅកែទាំងនោះជាមិនខាន។

ដូចដែលបានលើកឡើងខាងលើ រដ្ឋមិនមានលទ្ធផលក្នុងការទាមទារឲ្យអនុវត្តទៅតាមច្បាប់នោះទេ ដោយហេតុគ្រប់គ្នាសុទ្ធតែបានដឹងថាមិនអាចធ្វើទៅបាន។ មិនមានគណបក្សនយោបាយណាមួយ ក្នុងការធ្វើឲ្យមានប្រសិទ្ធភាពក្នុងការធ្វើនយោបាយនូបនីយកម្ម នៅក្នុងយុទ្ធនាការឃោសនានីមួយៗនោះទេ។ សន្ទស្សន៍មួយនៃផលវិបាកដែលអាចនឹងកើតមាននៅតារាងទី១។ នៅឆ្នាំ ១៩៥៣ នៅពេលដែលសង្គ្រាម ត្រជាក់បានពង្រីកឥទ្ធិពលនោះ គណបក្សសេរី និងប្រជាធិបតេយ្យ បានធ្វើរបាយការណ៍ចំណូលរបស់ខ្លួន ដែលមាន ២០ លើក ធៀបនឹងគណបក្សកុំម្មុយនីស្តដែលជាគណបក្សមួយដែលលើកតម្កើងខ្លួនថា ស្មោះត្រង់។ ផ្ទុយទៅវិញ នៅទសវត្សឆ្នាំ ១៩៩០ នៅពេលដែលពួកកុំម្មុយនីស្តចុះខ្សោយ នៅពេលនោះហើយដែលគណបក្សនេះ ជាគណបក្សដែលបាន



ធ្វើការប្រកាសពីចំណូលដ៏ច្រើនសន្ធឹកសន្ធាប់របស់ខ្លួន គឺថា មានច្រើនជាងគណបក្សប្រជាធិបតេយ្យបានធ្វើរបាយការណ៍ចំណូលរបស់ខ្លួន ដែលមាន ២០ លើក ធៀបនឹងគណបក្ស កុំម្មុយនីស្ត ដែលជាគណបក្សមួយដែលលើកតម្កើងខ្លួនថា ស្មោះត្រង់។ ផ្ទុយទៅវិញ នៅទសវត្សឆ្នាំ ១៩៩០ នៅពេលដែលពួកកុំម្មុយនីស្តចុះខ្សោយ នៅពេលនោះ ហើយដែលគណបក្សនេះ ជាគណបក្សដែលបានធ្វើការប្រកាសពីចំណូលដ៏ច្រើនសន្ធឹកសន្ធាប់របស់ខ្លួនគឺថា មានច្រើនជាងគណបក្សប្រជាធិបតេយ្យសេរី ដែលគាំទ្រក្រុមពាណិជ្ជកររហូតដល់ ២០% នៅតារាងទី២។

ទោះបីជាយ៉ាងណាគណបក្សប្រជាធិបតេយ្យសេរី បានប្រកាសឲ្យដឹងពីចំនួនសរុបនៃចំណូលរបស់ខ្លួន រួមទាំង សាខាគណបក្សថ្នាក់មូលដ្ឋាន និង ចំនួនថវិកាដែលសល់តាំងពីឆ្នាំមុនៗ ប្រមាណ **១៤០ លានយ៉េន** ក្នុងឆ្នាំ២០០០។ មានអ្នកអង្កេតការណ៍ជាច្រើនមាន មន្ទិលសង្ស័យថា ចំណូលពិតប្រាកដរបស់គណបក្សនេះ មានប្រមាណជាង ៥ ដង នៃរបាយការណ៍ដែលបានបង្ហាញដោយ (Hrebenar 2000:61)។

វាជាការពិត ដែលធនធានគណបក្សនយោបាយដ៏ច្រើនបែបនេះ ពេលបណ្តាលឲ្យកើតរឿងអាស្រូវ ដែលគួរឲ្យកត់សម្គាល់ (រឿងអាស្រូវរបស់ Tanaka Lockheed នៅទសវត្សឆ្នាំ ១៩៧០)។ បញ្ហាទាំងនេះ បាននាំឲ្យមានការប្រឆាំងជាសាធារណៈ និងមានការរឹតបន្តឹងលើផ្លូវច្បាប់។ ប៉ុន្តែយ៉ាងហោចណាស់ នៅពេលនោះ គណបក្សប្រជាធិបតេយ្យសេរី បង្ហាញពីជំនាញក្នុងកិច្ចការសាធារណៈ ដែលធ្វើឲ្យក្រុមគណបក្សតូចតាច គ្មានភាពរីកចំរើន។

លោក **មីគី តាកែវ** (Miki Takeo) ក្លាយជានាយករដ្ឋមន្ត្រី គ្រាន់តែជារូបភាពខាងក្រៅនៃការផ្លាស់ប្តូរផ្នត់គំនិត។ ហើយលោក **មីគី** បានធ្វើមានការអនុវត្តនូវនិយតកម្មនៃមូលនិធិនៅពេលយុទ្ធនាការឃោសនាបោះឆ្នោត។ ទោះជាយ៉ាងនេះក៏ដោយមិនយូរប៉ុន្មានគាត់ត្រូវបានទម្លាក់ពីតំណែងដោយក្រុមមេដឹកនាំដែលមិនសប្បាយចិត្តរបស់ក្រុមភាគច្រើន ដែលខកខានមិនបានការពារកាត់ទោសអតីតនាយករដ្ឋមន្ត្រីតាណាកា។ វិធានទាំងឡាយមិនមានភាពលម្អៀងទៅគណបក្សណាមួយទេ។ ជាការពិតរយៈពេល២-៣ឆ្នាំ ក្រោយសង្គ្រាមរដ្ឋបាលរបស់លោក Alied បានព្យាយាមផ្តាប់ចិត្តគណបក្សសង្គមនិយម ដោយសារគេគិតថា វាមានសក្តានុពលសំខាន់ជារបងការពារធម្មនុញ្ញសន្តិភាពថ្មី ដែលហាមប្រាមជប៉ុន មិនឲ្យមានកងកម្លាំងផ្ទាល់ខ្លួន ដែលធ្វើឲ្យគណបក្សសង្គមនិយមដាច់ឆ្ងាយពីគណបក្សកុំម្មុនីស្ត។

### ៤- សេចក្តីស្នើកែទម្រង់នៅជប៉ុន បោះឆ្នោតជាតិឆ្នាំ ១៩៩៦

នៅជប៉ុន បញ្ហាធំនៃរឿងអាស្រូវពីថវិកានៅទសវត្សឆ្នាំ ១៩៩០ ទីបំផុតធ្វើឲ្យគណបក្ស LDP ព្យាយាម ដោះស្រាយបញ្ហានោះ បើទោះបីជាទីបំផុតធ្វើឲ្យពួកគេបាត់បង់អំណាច នៅឆ្នាំ ១៩៩៣ ក៏ដោយ ប៉ុន្តែជាជម្រើសក្នុងការកែទម្រង់ក្នុងរដ្ឋាភិបាលចំរុះដែលដឹកនាំដោយ គណបក្សជំទាស់បង្កើតថ្មី Shinshinto ដែលផ្តើមវិធានការទាំងនោះ។ បញ្ហាសំខាន់នៅឆ្នាំ ១៩៩៩ គឺការធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងមូលនិធិគណបក្សនយោបាយឆ្នាំ ១៩៤៨។ ជាមូលដ្ឋាន នៃវិធានការនេះ គឺសំអាងលើ តួនាទីរបស់រដ្ឋក្នុងការធ្វើ និយ័តកម្ម លើសកម្មភាពគណបក្សនយោបាយ។ ក្រុមហ៊ុននានាគឺមិនត្រូវបានអនុញ្ញាតឲ្យផ្តល់ថវិកាដល់បេក្ខជន ម្នាក់ៗនោះទេ ប៉ុន្តែអនុញ្ញាតដល់គណបក្សនយោបាយ និងអង្គការនយោបាយដែលត្រូវបានគេទទួលស្គាល់។ ឥឡូវនេះ ចំពោះការផ្តល់ថវិកាច្រើនជាង ៥០ ០០០ យ៉េនជប៉ុន (៥០០ដុល្លារអាមេរិក) ត្រូវតែមានរបាយការណ៍ ដែលពីមុននេះ អនុញ្ញាតបានរហូតដល់ ១.០០០.០០០ យ៉េនជប៉ុន។ នេះមានន័យថា គឺជាទោសប្បញ្ញត្តិបន្ថែមចំពោះការរំលោភលើវិធានផ្សេង។ ពីមុន បេក្ខជនដែលទទួលបានជោគជ័យអាចនឹងត្រូវមោឃភាព ប្រសិនបើអ្នកឃោសនា ឬអ្នកគ្រប់គ្រងការឃោសនាត្រូវបានគេរកឃើញថា មានការពាក់ពន្ធ័។ ឥឡូវនេះបើរកឃើញថា អ្នកឃោសនាណាម្នាក់រំលោភច្បាប់ នោះលទ្ធផលឆ្នោតដែលជននោះទទួលបាននឹងត្រូវចាត់ទុកជាមោឃភាព។

បទប្បញ្ញត្តិជាច្រើនដែលមានក្នុងនិយ័តកម្មថ្មីនេះ គឺមានគោលដៅពង្រឹងគណបក្សនយោបាយ លើការចំណាយរបស់ក្រុម និងបុគ្គលនៃគណបក្សនយោបាយ ដោយរំពឹងថា និយ័តកម្មថ្មីនេះ ជួយទ្រទ្រង់ដល់ កិច្ចពិភាក្សាលើគោលនយោបាយតម្រង់ទិស និងការវិវត្តន៍ នៃគណបក្សនយោបាយ ដើម្បីឲ្យទៅជាស្ថាប័ន មួយដែលមិនមានលក្ខណៈជាបុគ្គល។ វាគួរតែឈាន

ទៅដល់មូលនិធិ សម្រាប់គណបក្សនយោបាយ ដែលអាចចាត់ចែងដោយថ្នាក់ដឹកនាំរបស់គណបក្សនេះ ដែលអាចធ្វើឲ្យពួកគេអាចអនុវត្តអំណាចជាអ្នកដឹកនាំពិតប្រាកដលើអ្នកគាំទ្ររបស់ពួកគេ។

មតិផ្ទុយពីការរៀបចំទាំងនេះ គឺថា អន្តរាគមន៍របស់រដ្ឋមិនមែនដោយសារ មិនមានថវិកាគ្រប់គ្រាន់ សម្រាប់គណបក្សនយោបាយចាត់ចែងការបោះឆ្នោតនោះទេ ប៉ុន្តែការពិតដោយសារតែភាពខ្សោយ ក្នុងការចាត់ចែងរបស់គណបក្សនយោបាយទៅវិញទេ។ រដ្ឋអាចត្រឹមតែមានលទ្ធភាពធ្វើឲ្យមានរបៀបរៀបរយលើសកម្មភាពរបស់គណបក្សនយោបាយជាជាងការផ្ដល់ថវិកាដល់គណបក្សនោះ ហើយទាមទារឲ្យមានគណនេយ្យភាពពិតប្រាកដលើការចាត់ចែងថវិកានោះ។ ដូចនេះនៅពេលដែលការព្រួយបារម្ភខាងដើមពីសេចក្ដីត្រូវការអាចឲ្យគណបក្សបិតបេរបានដើម្បីទ្រទ្រង់ប្រជាធិបតេយ្យ។ ឥឡូវអ្វីបានផ្លាស់ប្ដូរដែលធ្វើឲ្យត្រូវអន្តរាគមន៍ ដើម្បីជួយគណបក្សនយោបាយក្នុងការកែទម្រង់ឲ្យដើរតួនាទីមានប្រយោជន៍ជាងនេះ និងមានប្រសិទ្ធភាពដែលជាផ្នែកមួយនៃប្រព័ន្ធប្រជាធិបតេយ្យ។

ទោះជាយ៉ាងនេះក៏ដោយ ច្បាប់គ្រប់គ្រងមូលនិធិគណបក្សនយោបាយត្រូវបានគេកែសម្រួល ដើម្បីការពារប្រតិបត្តិការផ្ដល់មូលនិធិដល់បេក្ខជនម្នាក់ និង Koenkai របស់ពួកគេតាំងពីឆ្នាំ ២០០០ មកម្ល៉េះ ផ្ទុយទៅវិញ ពួកគេអាចត្រឹមតែផ្ដល់មូលនិធិដល់សាខាមូលដ្ឋាន របស់គណបក្សនយោបាយទាំងនោះតែប៉ុណ្ណោះ។ តែគេមើលឃើញថា អ្នកកាន់កាប់មុខងារនៃគណបក្សទាំងនោះនៅតែមានអធិបតីភាពលើសាខាមូលដ្ឋាន នៃគណបក្សទាំងនោះដដែល ដែលធ្វើឲ្យការដឹកនាំនៅស្នាក់ការកណ្ដាលនៃគណបក្សនៅតែមានអានុភាព។

ជាងនេះទៅទៀត ការលេចធ្លាយត្រូវទម្លាយឲ្យដឹងនៅឆ្នាំ ២០០២ ដោយមេដឹកនាំរបស់គណបក្សកុំម្មុយនីស្តជប៉ុន Shii Kazho ដែលបរិហារថា កំឡុងពេល ១៤ខែនៃឆ្នាំ **១៩៩១-១៩៩២** រដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រី Miyazava Kiichi បានបែងចែក ១៤៣.៤៧លាន យ៉េនជប៉ុន (១ លានដុល្លារសហរដ្ឋអាមេរិក) ក្នុង **ឆន្ទានុសិទ្ធិថវិកា** សម្រាប់គណបក្សគ្រប់គ្រងអំណាច និងតំណាងរបស់គណបក្សប្រឆាំងក៏ដូចជា ការចំណាយបុគ្គលផ្សេងៗ នៅលំនៅឋានផ្លូវការរបស់គាត់។ ករណីនេះ ពេលខ្លះត្រូវបានគេប្រើប្រាស់ ជាស្ពាន ក្នុងការអនុម័តច្បាប់ផ្សេងៗរបស់រដ្ឋាភិបាលតាមរយៈ Diet ...។



លោក មីគី តាកែវ (Miki Takeo)



ការឃោសនាបោះឆ្នោតឆ្នាំ ២០០៩ នៅប្រទេសជប៉ុន

តារាងទី ១

| របាយការណ៍ចំណូលគណបក្សនយោបាយជប៉ុន ឆ្នាំ ១៩៥៣ (គិតជាលានយ៉េន) | |
|---|---|
| គណបក្ស | ចំណូល |
| សេរី (រួមទាំង ប្រជាធិបតេយ្យ) | ២២ ៩២៦ |
| ប្រូ្រគ្រេស៊ីវ (Progressive) | ១ ០៨៧ |
| សង្គមនិយម (ស្តាំនិយម) | ២ ៩២៧ |
| សង្គមនិយម (ឆ្វេងនិយម) | ២ ៥៥០ |
| កម្លាំងប្រជាកសិករ(Farmer-Labor) | ១០៧ |
| គ្រីនប្រឺស (Green Breeze) | ៥០៥ |
| កុំម្មុយនីស្ត | ១ ១០៥ |
| សរុបចំណូលដែលបានរាយការណ៍ | ៤០ ៩៩១ |

ប្រភព ៖ Ike, Nobutake, Japan Politics. New York: 1957:2001

តារាងទី ២

| របាយការណ៍ចំណូលគណបក្សនយោបាយជប៉ុននៅថ្នាក់ជាតិដោយឆ្នាំ (តួលេខគិតជា លានយ៉េន) | | | | | | |
|---|---|---|---|---|---|---|
| គណបក្សនយោបាយ | ឆ្នាំ ១៩៧៦ | ឆ្នាំ ១៩៨០ | ឆ្នាំ ១៩៨៥ | ឆ្នាំ ១៩៩០ | ឆ្នាំ ១៩៩៥ | ឆ្នាំ ២០០០ |
| កុំម្មុយនីស្ត | ១៥. ៩១៨ | ១៩. ៥៨២ | ២១. ៦៧៩ | ៣២. ០៥៨ | ៣១. ១០០ | ៣២. ៨០០ |
| ប្រជាធិបតេយ្យសេរី | ៧. ៨០៦ | ១៨. ៦៥៥ | ១៨. ៩៦៦ | ៣០. ៨៨៨ | ២៣. ៥០០ | ២៧. ១០០ |
| កូមេតូ | ៧. ១៣០ | ៨. ៣៨៨ | ៩. ៨០៧ | ១៣. ៨៩០ | ១៣. ៨០០ | ១៥. ៩០០ |
| សង្គមនិយមជប៉ុន | ៣. ៨៧៨ | ៥. ១១០ | ៦. ៦៨៩ | ៦. ៧៩៨ | ១៨. ៦០០ | ៤. ៨០០ |
| ប្រជាធិបតេយ្យសង្គមនិយម | ១. ៣៥០ | ២. ៨៦៣ | ១. ៨៣០ | ២. ៨១២ | N/A | N/A |
| ន្ញូហ្វ្រន់ធៀរ | N/A | N/A | N/A | N/A | ១៧. ៥០០ | N/A |
| ន្ញូសាគីចាកិ | N/A | N/A | N/A | N/A | ១. ៥០០ | N/A |
| ប្រជាធិបតេយ្យជប៉ុន | N/A | N/A | N/A | N/A | N/A | ១១. ០០០ |
| សេរី | N/A | N/A | N/A | N/A | N/A | ៣. ៨០០ |

Note : N/A = Not available or not applicable (party did not exist at the date in question)

Source : Japanese Ministry of Home Affairs.



ភាពសម្ងាត់នៃឆន្ទានុសិទ្ធិថវិកាត្រូវបានគេមើលឃើញថា ជាទិដ្ឋភាពដ៏ទៀងទាត់ចំពោះវិស័យការទូត និងនយោបាយក្នុងស្រុករបស់ជប៉ុនរាប់ទសវត្សមកហើយ។ ថ្នាក់ដឹកនាំគណបក្សផ្សេងទៀតបានតវ៉ាថា រដ្ឋាភិបាល Miyazawa ទេ ដែលគួរតែត្រូវផ្ដោតការពិចារណាច្រើនជាងគណបក្ស JPY ដែលចំណាយខ្ជះខ្ជាយអស់ ១៤៤លានដុល្លាសហរដ្ឋអាមេរិកនោះ។ បញ្ហានេះបានជំរុញឲ្យការចាប់អារម្មណ៍កាន់តែខ្លាំង ពីបញ្ហាអំពើពុករលួយក្នុងវិស័យនយោបាយជប៉ុន ហើយការចាប់អារម្មណ៍នោះត្រូវបានពង្រឹងបន្ថែមទៀតដោយ ការលាលែងជាទៀងទាត់របស់សមាជិក Diet នៃគណបក្សនេះ ក្នុងទសវត្សឆ្នាំ ១៩៩០ រហូតដល់ បច្ចុប្បន្ន ជុំវិញការបរិហារជាច្រើនលើកច្រើនសារពើអំពើសកម្មភាពពុករលួយ។

ទោះបីជា អតីតរដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី ដូចជា អតីតអគ្គលេខាធិការនៃគណបក្ស LDP និងអតីតអ្នកតស៊ូក្នុងការដឹកនាំរបស់ គណបក្សនេះ ដូចជា Kato Koichi ត្រូវបានបង្ខំឲ្យលាលែងដែរ។ អ្នកកែទម្រង់ គឺលោក នាយករដ្ឋមន្ត្រី Hosokawa Morihir ត្រូវ បានបង្ខំឲ្យលាលែងនៅឆ្នាំ ១៩៩៤ ជុំវិញ រឿងអាស្រូវផ្ទាល់ខ្លួនពីបញ្ហាហិរញ្ញវត្ថុ។ តួលេខនាំមុខគឺ នៅក្នុងគណបក្ស សង្គមប្រជាធិបតេយ្យ គឺ លោក Tsujimoto Kiyomiដែលបានរិះគន់យ៉ាងខ្លាំងក្លាចំពោះអំពើពុករលួយលើវិស័យនយោបាយ ហើយដែលត្រូវបានបង្ខំឲ្យលាលែងនៅឆ្នាំ ២០០២ ដោយសារជំនិតរបស់គាត់បានប្រើប្រាស់មូលនិធិនយោបាយខុស។ មនុស្សជំនិតជាច្រើនរបស់អ្នកនយោបាយជាញឹកញយ ត្រូវបានរកឃើញថាមានការពាក់ពន្ធ័នឹងរឿងអាស្រូវនេះ ដែលគេសន្និដ្ឋថា អំពើពុករលួយ បានសាយភាយយ៉ាងខ្លាំងក្លាក្នុងមជ្ឈដ្ឋាននយោបាយ។

ដើម្បីប្រឆាំងទៅនឹងការកើនឡើងនៃអំពើអាក្រក់ពីសាធារណៈ នៅឆ្នាំ ២០០២ សមាជិកសភា៤ រូប បានស្ម័គ្រចិត្តក្នុងការបង្ហាញការចំណាយលើបញ្ហានយោបាយរបស់ពួកគេ។ ពួកគេម្នាក់ៗ បានបង្ហាញការចំណាយប្រមាណ ៤០ លាន យ៉េន (៣៧ ម៉ឺនដុល្លារសហរដ្ឋអាមេរិក) ប្រចាំឆ្នាំ។ ទោះបីជាយ៉ាងណា ទង្វើបែបនេះត្រូវបានស្វាគមន៍ដោយចាត់ទុកថា ជាជំហានដំបូង នៃដំណើរឆ្ពោះទៅរកការបើកទូលាយជាងនេះទៀត ហើយត្រូវបានកត់សម្គាល់ដែរថា សមាជិកផ្សេងទៀតនៃគណបក្ស LDP, Suzuki Muneo ដែលថ្មីៗ នេះត្រូវបានបង្ខំឲ្យលាលែងបានទទួលស្គាល់ថា បានជួយរកមូលនិធិប្រមាណ ៥០០ លានយ៉េន (៤.៦ លានដុល្លារសហរដ្ឋអាមេរិក) សម្រាប់ខ្លួនគាត់ និងសហការីរបស់គាត់ (Iwa Tomoaki 2002) ហើយកាសែត Asahi Shimbun បានលើកឡើងថា ជាមធ្យមសមាជិក LDP បានប្រើប្រាស់ប្រមាណ ៨៨ លានយ៉េន (៨១៧០០០ ដុល្លារសហរដ្ឋអាមេរិក) ក្នុងមួយឆ្នាំ។ ដូច្នេះ ចេតនាឲ្យមានការបើកទូលាយនោះគឺ ដើម្បីបង្កើនចលនារិះគន់ពីប្រជាពលរដ្ឋ។

ភាពចង់ដឹងចង់ឃើញមួយពីផ្ដែផ្ដានៃវិធានថ្មីទាំងនេះ ពិតជាបានបង្កើតឲ្យមានអស្ថិរភាពក្នុងចំណោមគណបក្សនានា ដូចនៅតារាងទី២។ តាំងពីមានការផ្ដល់ប្រាក់ឲ្យវិញចំពោះគណបក្សដែលបាន ទទួលអាសនៈយ៉ាងតិច ៥ នោះមក និងមូលនិធិត្រូវបានចាត់ចែងតាមឆ្នាំជាមូលដ្ឋាន នៅពេលចាប់ផ្ដើមឆ្នាំថ្មី នៃសារពើពន្ធនៅត្រីមាសទី១ដែលគេឃើញមានដដែលៗនូវវិវាទនិង ការបែកបាក់នៅក្នុងគណបក្ស នយោបាយ ដូចដែលក្រុមដែលមិនពេញចិត្តនោះ សម្រេចថា គួរផ្លាស់ប្ដូរការផ្ដល់ប្រាក់ឲ្យប្រាក់វិញនៅឆ្នាំក្រោយ។ នេះមិនគ្រាន់តែជាហេតុផលដែលធ្វើលេចចេញនូវគណបក្សថ្មីប៉ុណ្ណោះទេ ហើយសម្រាប់ថេរវេលាដ៏ខ្លីមួយនៃដំណើរការគណបក្សខ្លះនោះ តែវាគឺជាកត្តាដែលនាំឲ្យមាន ការបំបែកគណបក្សនយោបាយ។

ទោះបីជាយ៉ាងណា សមិទ្ធិផលមួយ ដែលបានកើតឡើងពីការផ្ដួចផ្ដើមនៃជំនួយរដ្ឋាភិបាលទៅលើ គណបក្សនយោបាយនៅទសវត្សឆ្នាំ ១៩៩០ គឺ វាបានធ្វើឲ្យបញ្ចប់រាល់ទម្រង់នៃការចំណាយច្រើន លើសកម្មភាពនយោបាយ ពីទសវត្សមុនៗ ទោះជាពេលនោះ គឺទសវត្សនៃភាពស្ងប់ស្ងៀមនៃសេដ្ឋកិច្ចជប៉ុន ដែលអាចជាកត្តារួមផ្សំក៏ដោយ។

នៅមានត...



# ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុង រដូវកាលប្រជុំពេញអង្គ

## (ខែមេសា ខែឧសភា ខែមិថុនា និងខែកក្កដា ឆ្នាំ២០១០)



ក្រុមការងារខុមហ្វ្រែល អង្កេតមើលរដ្ឋាភិបាលតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ

នៅក្នុងខែមេសា ខែឧសភា និងខែមិថុនា ឆ្នាំ២០១០នេះ ដែលជាពេលរដ្ឋសភាចូលកង និងប្រជុំពេញអង្គឡើងវិញ សម្រាប់ឲ្យអ្នកតំណាងរាស្ត្រធ្វើការអនុម័តសេចក្ដីព្រាងច្បាប់ផ្សេងៗ ហើយខែកក្កដា នៃវិស្សមកាលរបស់តំណាងរាស្ត្រសម្រាប់ចុះជួបប្រជាជន **ខុមហ្វ្រែល** អង្កេតឃើញថា មិនសូវមានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានប៉ុន្មានទេ។ មានអ្នកតំណាងរាស្ត្រចំនួន **៧៦ រូប** មកពីគណបក្សជាប់ឆ្នោត ៤ (លើកលែងគណបក្សជាតិនិយម) បានចុះមូលដ្ឋាន បានចំនួន **៤១០ លើក។**

**អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា** ចំនួនយ៉ាងតិច **៥៥ រូប** (ស្មើនឹង ៦១% នៃតំណាងរាស្ត្រសរុប ៩០ រូប) បានចុះមូលដ្ឋាន ចំនួន **២៥៥ លើក** ឬជាមធ្យមអ្នកតំណាងរាស្ត្រមួយរូប ចុះមូលដ្ឋានចំនួន ៥ លើក។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលមាន **៣ រូប** ចុះមូលដ្ឋានតែមួយរូប ស្មើនឹង ១០០ % បានចំនួន ១៦ លើក ឬជាមធ្យមអ្នកតំណាងរាស្តម្នាក់ ចុះមូលដ្ឋានបាន **៦ លើក។** ខណៈដែលតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានចុះមូលដ្ឋានចំនួន **១៦ រូប** (ស្មើនឹង ៦២% នៃអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីសរុប ២៦ នាក់) បានចុះមូលដ្ឋានសរុបតែ **១៣៤ លើក** មានន័យជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះ មួយរូបចុះមូលដ្ឋានបាន ៩ លើក។ ចំណែកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច **១ រូប** បានចុះចំនួន **២ លើក** (៥០% នៃអ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច សរុប)។

**ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង**

| គោលបំណងនៃការចុះមូលដ្ឋានទាំង ៤១០លើក របស់តំណាងរាស្ត្រទាំង ៧៦រូប | គណបក្សនយោបាយ | | | | | សរុបនៃគោលបំណង |
|---|---|---|---|---|---|---|
| | ៥៥រូប | ១៦រូប | ៣រូប | ១រូប | ១រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិង ការសម្ពោធសមិទ្ធផលនានា | ១៥១ | ៤៣ | ៥ | ០ | ០ | ១៩៩ (៤៨%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស | ៧០ | ៧៧ | ៨ | ២ | ២ | ១៥៩ (៣៩%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២៧ | ០ | ០ | ០ | ០ | ២៧ (៧%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ២ | ១០ | ៣ | ១ | ០ | ១៦ (៤%) |
| ការអន្តរាគមន៍ និង ដោះស្រាយបញ្ហានានា | ៥ | ៤ | ០ | ០ | ០ | ៩ (២%) |
| សរុបជាភាគរយៈតាមគណបក្ស | ២៥៥ (៦១%) | ១៣៤ (៣៣%) | ១៦ (៤%) | ៣ (១%) | ២ (១%) | ៤១០ (១០០%) |



តាមតារាងដែលជាព័ត៌មាន បានបង្ហាញថា អ្នកតំណាងរាស្ត្រ ភាគច្រើនចុះមូលដ្ឋានផ្ដោតទៅលើ ការចុះសួរសុខ ទុក្ខប្រជាជន និងចែកអំណោយរហូតដល់ ៤៨% (ស្មើនឹង ១៩៩ លើក) និងចុះពង្រឹងផ្ទៃក្នុងគណបក្ស ៣៩% (ស្មើនឹង ១៥៩ លើក)។ ខណៈដែលការចុះអន្តរាគមន៍ មានតែ ២% (៩ លើក) និងការអមដំណើរថ្នាក់ដឹកនាំ ស្មើនឹង ៧ % (២៧ លើក)។ ចំណែកការចូលរួមក្នុងវេទិកាសាធារណៈ មានការកើនឡើងស្មើនឹង ១៦ លើក (៤%)។

» **ការសាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធគម្រោងនានា** ៖ ត្រូវបានធ្វើឡើងដោយតំណាងរាស្ត្រមកពី ៣ គណបក្ស ដែលគណបក្សប្រជាជនកម្ពុជា ឈានមុខគេ ចំនួន **១៥១ លើក** លើគណបក្សសមរង្ស៊ី ដែលចុះមូលដ្ឋានដើម្បីសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធ


តំណាងរាស្ត្រ ឡើងបញ្ចេញមតិក្នុងពេលប្រជុំពេញអង្គនៃរដ្ឋសភា

គម្រោងនានា សរុប ៤៣ លើក និងគណបក្សសិទ្ធិមនុស្ស ចំនួន **៥ លើក។** ជាក់ស្ដែង អ្នកតំណាងរាស្ត្រ **ស ខេង** មណ្ឌលបាត់ដំបង របស់គណបក្សប្រជាជនកម្ពុជា បាននាំមុខគេទីពីរ អញ្ជើញជាអធិបតី ក្នុងពិធីសម្ពោធសមិទ្ធផលក្នុងឃុំតាគ្រាម ស្រុកបាណន់ ហើយចែកអំណោយឧបត្ថម្ភដល់កម្លាំងប្រដាប់អាវុធ និងយាយជី តាជី ពលរដ្ឋ សរុបចំនួន **៨៣៧ នាក់** (ម្នាក់ៗ ទទួលបាន សារុង មួយ) នៅថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១០។ អ្នកតំណាងរាស្ត្រ **ម៉ែន សុថាវរិន្ទ្រ** គណបក្សសមរង្ស៊ី មណ្ឌលកំពង់ធំ បានឈានមុខគេ ក្នុងបក្សបានចុះមូលដ្ឋានចំនួន ៨ លើក ជាក់ស្ដែងកាលពីថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១០ ឯកឧត្ដម បានអញ្ជើញចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ២០០ នាក់ នៅភូមិក្ដីតាចិន ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលនៅក្នុងការសំណេះសំណាលនោះ តំណាងរាស្ត្ររូបនេះ បាននាំយកនូវការផ្ដាំផ្ញើ និងការនឹករលឹកពីសំណាក់ឯកឧត្ដម សម រង្ស៊ី ខណៈដែលប្រធានគណបក្សសមរង្ស៊ី កំពុងនៅក្រៅប្រទេស។ អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញាឫទ្ធិ** របស់គណបក្សសិទ្ធិមនុស្សមណ្ឌលព្រៃវែង កាលពីថ្ងៃទី **១៤ ខែឧសភា ឆ្នាំ២០១០** បានចុះទៅវត្តអំបែងចេះ ឃុំលេ ស្រុកស៊ីធរកណ្ដាល គោលបំណងសួរសុខទុក្ខសកម្មជន និងប្រជាពលរដ្ឋជាង ៤០០ នាក់ ចូលរួម។ នៅថ្ងៃខែដដែល ចុះសួរសុខទុក្ខសកម្មជន ពលរដ្ឋនៅឃុំត្នោត ស្រុកកញ្ជ្រៀច មានភ្ញៀវចូលរួមប្រហែល ៣០០ នាក់។

» **ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស** ៖ តំណាងរាស្ត្រមកពី ៥ គណបក្ស បានចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សរបស់ខ្លួន ចំនួន ១៥៩ លើក ដែលគណបក្សសមរង្ស៊ី ឈានមុនគេដល់ទៅ ៧៧ លើក គណបក្សប្រជាជនកម្ពុជា បានចុះ ៧០ លើក និងគណបក្ស


(រូបភាព ៖ ខុមហ្វ្រែល): វេទិកាម្ចាស់ឆ្នោត កាលពី ខែកក្កដា ឆ្នាំ២០១០ នៅខេត្តកំពត

សិទ្ធិមនុស្ស ៨ លើក គណបក្សហ៊្វុន ស៊ិនប៉ិច និងគណបក្សជាតិនិយម មានចំនួន ២ ដង ផងដែរ។ យ៉ាងណាមិញ អ្នកតំណាងរាស្ត្រ **យន្ត ថារ៉ូ** មណ្ឌលបន្ទាយមានជ័យ របស់គណបក្សសមរង្ស៊ី បានចូលរួមប្រជុំថ្នាក់ដឹកនាំចលនាយុវជន នៅទីស្នាក់ការគណបក្សខេត្ត នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១០។ ចំណែក អ្នកតំណាងរាស្ត្រ **ឡោង ខេង** មណ្ឌលភ្នំពេញ របស់គណបក្សប្រជាជនកម្ពុជា បានចុះទៅជួបសួរទុក្ខ និងនាំក្រុមពេទ្យស្ម័គ្រចិត្ត សាលារាជធានីភ្នំពេញ ពិនិត្យព្យាបាលសុខភាព ជូន សមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា ដែលជាសមាជិកក្រុមប្រឹក្សា សង្កាត់ ភូមិ និងមេ ៥០ ខ្នង ចំនួន ១៥០ នាក់ នៅខណ្ឌសែនសុខ ក្រុងភ្នំពេញ ព្រមទាំងឧបត្ថម្ភ ម្សៅបំប៉នសុខភាពម្នាក់ ១ កំប៉ុង និងថវិកាចំនួន ១០០០០ (មួយម៉ឺន) រៀល កាលពីថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១០)។ ចំណែកអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស **យ៉ែម ប៉ុញ្ញាឫទ្ធិ** មណ្ឌលព្រៃវែង

បានចុះទៅស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដើម្បីចូលរួមប្រជុំនៅស្នាក់ការគណៈខេត្ត គោលបំណងសួរសុខទុក្ខ ពង្រឹងសកម្មជន និងធ្វើផែនការទិសដៅខាងមុខ កាលពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១០ ដែលមានភ្ញៀវចូលរួមចំនួន ២៦ រូប។

កាលពីថ្ងៃទី ១៨ ខែកក្កដា អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច **ញ៉ឹក ប៊ុនឆៃ** មណ្ឌលបន្ទាយមានជ័យ និងអ្នកតំណាងរាស្ត្រ គណបក្សជាតិនិយម **សៅ រ៉ានី** មណ្ឌលព្រៃវែង បានចូលរួមប្រជុំនៅស្នាក់ការគណបក្សខេត្តបន្ទាយមានជ័យ ស្ដីពីការបញ្ចុះបញ្ចូលសម្ពន្ធ័ភាពគណបក្សទាំងពីរ ដែលមានអ្នកចូលរួមប្រមាណ ៣៧០ នាក់ ដោយក្នុងនោះ មានការទទួលទាន បាយមួយពេល និងថែមប្រាក់ដល់អ្នកចូលរួមម្នាក់ ៥០០០ (ប្រាំពាន់)



ទិដ្ឋភាពអ្នកចូលរួមវេទិកាម្ចាស់ឆ្នោតនៅខេត្តសៀមរាប

រៀល សម្រាប់ការធ្វើដំណើរផងដែរ។

» **ការចុះអមដំណើរថ្នាក់ដឹកនាំ** ៖ មានតែគណបក្សប្រជាជនកម្ពុជាទេ ដែលមានសកម្មភាពអមដំណើរថ្នាក់ដឹកនាំសរុបបាន ២៧ ដង ជាក់ស្ដែង កាលពីថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង ៧.៣០នាទី ព្រឹក អ្នកតំណាងរាស្ត្រ **លី គីមលៀង** បាននាំមុខ ក្នុងការអមដំណើរឯកឧត្ដម **ស ខេង** ចុះទៅជួបសំណេះសំណាល និងសួរសុខទុក្ខពលរដ្ឋចំនួន ២៥៣ គ្រួសារ ដែលរងគ្រោះដោយសារខ្យល់ព្យុះនៅស្រុកសំពៅលូន ខេត្តបាត់ដំបង។

» **ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា** ៖ តំណាងរាស្ត្រគណបក្សសមរង្ស៊ី និងគណបក្សប្រជាជនកម្ពុជា បានចុះមូលដ្ឋាន ដើម្បីអន្តរាគមន៍ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ចំនួន ៩ លើក ដែលរួមមាន ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា **កាទើ តូយ៉េប** មណ្ឌលក្រចេះ បានជួយសម្រួលបញ្ហាដីធ្លីដែលបានកាប់ឆ្ការរួចហើយ នៅភូមិបុសខ្នុរ ឃុំកញ្ជរ ស្រុកឆ្លង ដែលត្រូវបានក្រុមហ៊ុនកាសទីម គំរាមកាលពីថ្ងៃទី ៦ ខែមេសា ឆ្នាំ២០១០។ ចំណែក អ្នកតំណាងរាស្ត្រ នុត រំដួល តំណាងរាស្ត្រគណបក្សសមរង្ស៊ី មណ្ឌលកំពង់ស្ពឺ បានចុះអន្តរាគមន៍ជួយប្រជាពលរដ្ឋ ២ នាក់ ដែលត្រូវតុលាការចាប់ខ្លួន[ថ្ងៃទី ២១ ខែមេសា ២០១០] ក្រោយពេលតុលាការកោះហៅ មកសាកសួរពាក់ពន្ធ័នឹងរឿងទំនាស់ដីធ្លី ជាមួយនឹងក្រុមហ៊ុន លី យ៉ុងផាត់ នៅឃុំអមលាំង ស្រុកថ្លង់ ខេត្តកំពង់ស្ពឺ។

» **ការចូលរួមក្នុងវេទិការសាធារណៈរបស់អង្គការក្រៅរដ្ឋាភិបាល** ៖ មានការចូលរួមពីតំណាងរាស្ត្រទាំង ៤ គណបក្ស។ អ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ី នុត រំដួល បានចូលរួមវេទិកាសាធារណៈចំនួន ១ លើក កាលពីថ្ងៃទី ៣០ មេសា ដែលរៀបចំ ឡើងដោយ ខុមហ្វ្រែល ស្ដីពី



(រូបភាព ៖ ខុមហ្វ្រែល): វេទិកាម្ចាស់ឆ្នោត កាលពី ខែកក្កដា ឆ្នាំ២០១០ នៅខេត្តសៀមរាប

ការវាយតម្លៃលទ្ធផលរបស់ម្ចាស់ឆ្នោត ទៅលើការអនុវត្តលក្ខខណ្ឌសន្ទស្សន៍ នៃវិស័យអាទិភាព ក្នុងខេត្តកំពង់ស្ពឺ ដែលមានប្រជាជនចូលរួម ចំនួន ៨៥ នាក់។ អ្នកតំណាងរាស្ត្រ **ជួញ សុផៃ** បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅវត្តតាពូង ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ដែលរៀបចំដោយអង្គការ អិនឌីអាយ កាលពីថ្ងៃទី ៣ មេសា ២០១០។ អ្នកតំណាងរាស្ត្រ អ៊ូ ចន្ទ័ឫទ្ធិ គណបក្សសមរង្ស៊ី មណ្ឌលកណ្ដាល និងអ្នកតំណាងរាស្ត្រ **សៅ រ៉ានី** គណបក្សជាតិនិយមមណ្ឌលព្រៃវែង បានបើកវេទិកាសាធារណៈ ក្រោមប្រធានបទសិទ្ធិមនុស្ស និងការអភិវឌ្ឍ នៅភូមិថ្នល់បទ ឃុំអមលាំង ស្រុកថ្លង់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ២០ ឧសភា ២០១០ ដែលមានពលរដ្ឋប្រមាណ ៥០០ បាននាក់ចូលរួម៕







កំណាព្យ

## ដោះលែង ឬដាក់ ដាក់គុក?

តាក់តែងដោយ ៖ វិច្ឆិកា

១. រឿងច្បាប់ស្រុកខ្មែរ ក្មេងក៏ដឹងដែរ សភាពដូចទោង
ម្ដងរេទៅជើង ម្ដងយោលទៅត្បូង ម្ដងរាបជូនប៉ោង
មិនសូវតោងច្បាប់។

២. ទោសត្រឹមលួចមាន់ នៅពេលម្ចាស់ទាន់ ជ្រុលដៃសម្លាប់
ព្រោះទ្រាំមិនបាន ប្រានគ្នាចូលចាប់ វាយដំច្រំស្លាប់
ច្បាប់ចាប់ដាក់គុក។

៣ អ្នកក្រតូចតាច តែងតែខ្លបខ្លាច អំណាចអភិជន
ព្រោះអ្នកក្រខុស តែងមានទោសធ្ងន់ ដូចទឹកឡើងជន់
ជោរលិចតែស្មៅ។

៤ រីអ្នកមានយស អំណាចខ្ពង់ខ្ពស់ ដូចផ្ទឹកស្រឡៅ
មិនសូវលិចលង់ ដោយសារទឹកជ្រៅ ពោលគឺដង្ហៅ
មិនចាញ់កម្មករ។

៥. ឧក្រិដ្ឋកម្មខ្លះ អ្នកធំពាររ៉ះ គេនៅតែល្អ
ជូនកែកាឡៃ ខ្មៅទៅជាស ឲ្យអ្នកក្រីក្រ
រងទទួលកម្ម។

៦. ដូចរឿងឧក្រិដ្ឋ ដែលកើតមានពិត យើងបានរង់ចាំ
ក្នុងរយៈពេល អស់សាមសិបឆ្នាំ ដែលខ្មែររង់ចាំ
មើលជនឧក្រិដ្ឋ។

៧. ដំបូងគេថា មានតុលាការ ផ្សះផ្សាផ្លូវចិត្ត
រីជនរងគ្រោះ ស្មានថាការពិត ក្ដីស្មានការគិត
ដូចជាយល់សុបិន។

៨. យើងបានឃើញច្បាស់ អគតិជ្រុលណាស់ ខ្មែរត្រូវប្រល័យ
ដោយមេឃាតក មុខអាក្រក់ក្រៃ ប្រហារឲ្យក្ស័យ
ខ្មែរទាំងម៉ឺននាក់។

៩. គុកសាមប្រាំឆ្នាំ ខ្មែរអើយចូរចាំ ទុកជាតម្រា
គេលើកទឹកចិត្ត ឃាតកហើយណា ឲ្យរឹតប្រហារ
ព្រោះច្បាប់ឡប់ឡែ។

១០. ជនដែលបានស្លាប់ ដប់ពីរពាន់ប្រាប់ ថាឈឺរឹតទ្វេ
ព្រោះស្លាប់មនុស្សម្នាក់ ទោសមួយថ្ងៃទេ ល្អមើលផងគេ
គួរឲ្យឈឺណាស់។

១១. តែអ្នកខ្លះថា បើបានជ្រុលចារ សម្រាលទោសប្រាណ
នៅដប់ប្រាំបួនឆ្នាំ គួរកុំរំខាន គួរដោះលែងប្រាណ
ឱចមានសេរី។

១២. ព្រោះនាំពិបាក ដុនដាបតោកយ៉ាក រឿងនំចំណី
រឿងថែការពារ ឱចទាំងយប់ថ្ងៃ ឲ្យមានសេរី
មិនបាច់ដាក់ទោស។

១៣. ការសម្រេចក្ដី យោងពាក្យប្រណី ខុសធ្ងន់សម្បើម
យោងថាមនុស្សចាស់ ឮហើយគួរឆ្អើម គួរស្អប់គួរខ្ពើម
កាត់ក្ដីយកនាម។

១៤. ដូចលើកទឹកចិត្ត ដល់ជនឧក្រិដ្ឋ ដៃប្រឡាក់ឈាម
ដែលសម្លាប់ខ្មែរ យកឈាមព្រួសបៀម ដែលមិនអាចស្មៀម
ចង់បានយុត្តិធម៌៕







# កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ

ពីខែមិថុនា ដល់ ខែសីហា ឆ្នាំ២០១០

## នយោបាយ និងសង្គម

**»»២៨ មិថុនា ២០១០** ៖ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា មិនបានចូលរួមក្នុងពិធីរម្លឹកខួបលើកទី៥៩ (២៨/០៦/១៩៥១ - ២៨/០៦/២០១០) ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា នារាជធានីភ្នំពេញទេ ដោយសារមានបញ្ហាសុខភាព។ ពិធីនេះប្រារព្ធឡើងក្រោមវត្តមានរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាមានលោក **ជា ស៊ីម** ប្រធានគណបក្ស និងលោក **ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា។


រូបភាព ៖ RFI (លោក ជា ស៊ីម និង លោក ហេង សំរិន ក្នុងពិធីរំលឹកខួបទី៥៩ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ២៨ មិថុនា ២០១០)


រូបភាព ៖ RFI (សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**»»២៩ មិថុនា ២០១០** ៖ រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានចេញសេចក្តីជូនដំណឹងមួយថា សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **បានឆ្លងជម្ងឺគ្រុនផ្តាសាយថ្មី** (AH1N1) ពីកិច្ចប្រជុំគណៈរដ្ឋមន្ត្រីមួយដែលបានធ្វើឡើងកាលពីថ្ងៃទី២៥ មិថុនា ២០១០។ ប្រកាសដដែលបានឲ្យដឹងទៀតថា កិច្ចប្រជុំនេះក៏បានបណ្តាលឲ្យមន្ត្រីរាជរដ្ឋាភិបាល ៥ រូបទៀត រួមមាន ឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ទេសរដ្ឋមន្ត្រី **ឆាយ ថន** ទេសរដ្ឋមន្ត្រី **តាវ សេងហួរ** លោក **គឹម អ៊ិត** លោក **អ៊ិត មិត** ឆ្លងជម្ងឺគ្រុនផ្តាសាយ (AH1N1) ផងដែរ។

**»»១៣ កក្កដា ២០១០** ៖ ប្រធានស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស លោកស្រី **ណាវី ភីល័យ** (Navy Pillay) បានហៅករណីលោកស្រី មូរ សុខហួរ ដែលតុលាការកម្ពុជាកាត់ក្តីឲ្យចាញ់លោកនាយករដ្ឋមន្ត្រី ហើយត្រូវសងប្រាក់ពិន័យ និងជំងឺចិត្តលោក ហ៊ុន សែន ចំនួន ១៦,៥លានរៀល ថា ជាការប្រកាសអាសន្នចំពោះការធ្លាក់ចុះសិទ្ធិសេរីភាពនៅប្រទេសកម្ពុជា។


រូបភាព ៖ AP (មហាសន្និបាតអង្គការសហប្រជាជាតិ)



រូបភាព ៖ RFA (ស្ថាប័នប្រឆាំងអំពើពុករលួយនៃព្រះរាជាណាចក្រកម្ពុជា)

**»»១៤ កក្កដា ២០១០** ៖ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ លោក **ឱម យ៉ិនទៀង** បានប្រកាសយកខែវិច្ឆិកា ២០១០ ដើម្បី ចាប់ផ្តើមនីតិវិធីប្រកាសទ្រព្យសម្បត្តិរបស់មេដឹកនាំរដ្ឋាភិបាល មន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ តំណាងរាស្ត្រ និងសមាជិកនៃព្រឹទ្ធ សភា មេដឹកនាំអង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជនធំៗ មន្ត្រីជាន់ខ្ពស់ និងព្រមទាំងមន្ត្រី និងសមាជិកនៃស្ថាប័នប្រឆាំងអំពើពុករលួយផងដែរ សរុបប្រមាណជាង **១០ ម៉ឺននាក់។**

**»»៣០ កក្កដា ២០១០** ៖ **«លំហាត់យោធាពហុសាសន៍ ឬ ឆ្នាំអង្គរ ២០១០»** បានប្រកាសបិទជាផ្លូវការ ដោយក្រសួងការពារជាតិ នៅក្នុងបន្ទាយយោធាកងរថក្រោះ A.C.O នៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ លំហាត់យោធាពហុសាសន៍នេះ បានចាប់ផ្តើមតាំងពីថ្ងៃទី១២ ខែកក្កដា ដោយមានការចូលរួមហ្វឹកហាត់ ពីសំណាក់យោធាចំនួន **១.០៣៤** នាក់ មកពីប្រទេសចំនួន **២៦**





**រាប់ទាំងកម្ពុជា** សហរដ្ឋអាមេរិក និងប្រទេសចិនផងដែរ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងសមត្ថភាពក្នុងការថែរក្សាសន្តិភាពក្នុងតំបន់ និងពិភពលោក ។


រូបភាព ៖ RFA (លំហាត់យោធាពហុសាសន៍ ឬឆ្នាំអង្គរ ២០១០)


ព្រះសង្ឃនិមន្តឆាន់ថ្ងៃត្រង់ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ

**»» ០៥ កក្កដា ២០១០** ៖ សង្ឃនាយកនៃប្រទេសកម្ពុជា ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** មានព្រះថេរដីកាថា នឹងរឹតបន្តឹងវិន័យ ហើយមិនអនុញ្ញាតឲ្យមានព្រះសង្ឃធ្វើពិធីមន្តអាគមគាថានៅក្នុងវត្តស្រះចកទៀតឡើយ។ ការហាមបែបនេះ បានធ្វើឡើងក្រោយពីរឿងអាស្រូវអាសអាភាសនៅក្នុងវត្តស្រះចក បានផ្ទុះឡើងធ្វើឲ្យកក្រើកអ្នករស់នៅក្នុងទីក្រុងភ្នំពេញ កាលពីចុងខែមិថុនា ដោយសារតែអតីតព្រះសង្ឃ ព្រះនាម **នេត ខៃ** ដែលចេះមន្តអាគមអូមអាម បាន **លួចលាក់ថតរូបស្រីៗអាក្រាតកាយចំនួន ៦០០ នាក់** ពេលកំពុងមុជទឹកមន្ត នៅពេលដែលស្រីៗទាំងនោះទៅរកអន្ទិតនេះឲ្យជួយធ្វើមន្តអាគមស្នេហ៍ស្នេហ៍ស្ទួក។

**»» ៨ សីហា ២០១០** ៖ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានផ្ញើលិខិតយ៉ាងប្រញាប់បំផុតមួយ ជូនប្រធានក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ និងប្រធានសភាអង្គការសហប្រជាជាតិ នៅក្នុងទីក្រុងញូវយ៉ក (New York) សហរដ្ឋអាមេរិក ដើម្បីប្តឹងអំពីរឿងព្រំដែន និងប្រាសាទព្រះវិហារ ដោយសារតែថៃបានគំរាមប្រើកម្លាំងទ័ពដោះស្រាយ និងឈ្លានពានកម្ពុជា។ លិខិតការទូតនោះ បានពណ៌នាថា ផែនទីដែលបានចេញដោយគណៈកម្មាធិការបារាំង-សៀម គឺជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ ដែលតុលាការយុត្តិធម៌អន្តរជាតិ បានកាត់សេចក្តីឲ្យកម្ពុជាឈ្នះក្តី កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២។ ប្រាសាទព្រះវិហារស្ថិតនៅក្នុងបូរណភាពទឹកដីកម្ពុជា។ ប្រទេសថៃមានកាតព្វកិច្ចដកកងទ័ពចេញពីតំបន់ប្រាសាទ។



ប្រាសាទព្រះវិហាររបស់កម្ពុជា ដែលប្រទេសថៃសន្ទំចិត្តប៉ងយកធ្វើជាម្ចាស់



**»» ១៦ សីហា ២០១០** ៖ **ក្រុមការងារសង្គមស៊ីវិល ដើម្បីគណនេយ្យភាព និងតម្លាភាពសង្គម** បានប្រកាសបើកយុទ្ធនាការ ប្រឆាំងនឹងការយកលុយលើសកំណត់លើពន្ធផ្លូវក្នុងទូទាំងប្រទេសកម្ពុជា ដោយចាត់ទុកថា បាតុភាពអសកម្មទាំងនោះជាអំពើពុករលួយដ៏រ៉ាំរ៉ៃ តាមរយៈការប្រើប្រាស់តួនាទី និងសិទ្ធិអំណាចរបស់មន្ត្រីសាធារណៈ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ យុទ្ធនាការនេះ បានប្រកាសនូវទូរសព្ទ័ **០១៧ ៥៥៩ ១២២** ជាសាធារណៈ ដើម្បីរាយការណ៍អំពីអត្តសញ្ញាណរបស់មន្ត្រីពន្ធដារ ដែលហ៊ានយកប្រាក់លើសការកំណត់ពីតារាងប្រាក់ពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយអាចនឹងផ្សព្វផ្សាយតាមប្រពន្ធ័ឃោសនា នូវអត្តសញ្ញាណរបស់មន្ត្រីពន្ធដារនោះផងដែរ។

**»» ២៣ សីហា ២០១០** ៖ ព្រះមហាក្សត្រកម្ពុជា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** បានព្រះរាជទានព្រះរាជក្រឹត្យលេខ **នស/រកត/០៨១០/៦៩០** ចុះថ្ងៃទី២៣ សីហា ឆ្នាំ២០១០ បញ្ចប់មុខតំណែងលោក **ចាក់ស៊ីន ស៊ីណារ៉ាត្រា** ជា ទីប្រឹក្សា

ផ្ទាល់នាយករដ្ឋមន្ត្រីកម្ពុជា និងជាទីប្រឹក្សារដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកសេដ្ឋកិច្ច ដោយយោងតាមសំណើរបស់លោក ថាក់ស៊ីន និងសេចក្តីក្រាបបង្គំទូលស្នើរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយបញ្ជាក់មូលហេតុថា មានភារកិច្ចផ្ទាល់ខ្លួនច្រើន មិនអាចបំពេញកិច្ចការជាទីប្រឹក្សាកម្ពុជានេះបាន។


លោក **ថាក់ស៊ីន ស៊ីណាវ៉ាត្រា**

## ច្បាប់ និងតុលាការ


រូបភាព ៖ AP (កាំង ហ្គេកអ៊ាវ ហៅឌុច អតីតមេគុកទួលស្លែង ឬមន្ទីរ ស-២១)

**»» ២៦ កក្កដា ២០១០** ៖ អង្គជំនុំសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (**អ.វ.ត.ក**) បានប្រកាសសាលក្រមលើសំណុំរឿង០០១ ទាក់ទងនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅឌុច សម្រេចឲ្យជាប់ពន្ធនាគារ **៣៥ ឆ្នាំ។** ចំពោះការអនុវត្តទោស អ.វ.ត.ក ក៏បានសម្រាលទោសមកនៅត្រឹម ១៩ ឆ្នាំ ដោយសារ ឌុច ត្រូវបានឃុំខ្លួនមុនពេលសម្រេចទោសជាង ១១ ឆ្នាំ ហើយបានសហការល្អជាមួយនឹង អ.វ.ត.ក ក្នុងពេលបើកសវនាការ។ មេធាវីការពារ ឌុច លោក **ការ សាវុត្ថ** និងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី មានគម្រោងប្តឹងសារទុក្ខ ខណៈដែលមានប្រតិកម្មជាច្រើនអំពីសាលក្រមមួយនេះ។ តាមនីតិវិធី ភាគីទាំងសង្ខាង មានរយៈពេល ៣០ ថ្ងៃ ដើម្បីដាក់ពាក្យបណ្តឹង។


តំណាងរាស្ត្រស្រ្តីគណបក្សសមរង្ស៊ី មូរ សុខហួរ

**»» ២៩ កក្កដា ២០១០** ៖ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា បានសម្រេចកាត់ប្រាក់ខែរបស់ លោកជំទាវ **មួរ សុខហួរ** តំណាងរាស្ត្រស្រ្តីគណបក្សសមរង្ស៊ី ចំនួន (**ប្រាំបី លាន**) **៨ ០០០ ០០០** រៀល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់បង់សំណងជំងឺចិត្តដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រោយពេលលោកជំទាវ មូរ សុខហួរ ចាញ់ក្តីលើបណ្តឹងបរិហាកេរ្តិ៍ របស់លោកនាយករដ្ឋមន្ត្រី។


រូបភាព ៖ ខុមហ្វ្រែល (លោកជំទាវ មូរ សុខហួរ តំណាងរាស្ត្រ គណបក្សសមរង្ស៊ី)

**»» ១១ សីហា ២០១០** ៖ ឯកឧត្តម **ជាម យៀប** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានមានប្រសាសន៍ប្រាប់ប្រពន្ធ័ផ្សព្វផ្សាយថា រដ្ឋសភារឹបអូបប្រាក់ខែតំណាងរាស្ត្រលោកស្រី មូរ សុខហួរ ជាបន្ត ទៀត ចាប់ពីខែ សីហា នេះ ចំនួន **៨ លាន ៥ សែន រៀល** ដើម្បីបង់ប្រាក់ពិន័យទៅឲ្យរតនាគារជាតិកម្ពុជា តាមការស្នើសុំរបស់សាលាដំបូងរាជធានីភ្នំពេញ។ ការកាត់ប្រាក់ខែលើកទីពីរ ដែលនឹងចាប់ផ្តើមបន្តពីបំណុលប្រាក់សំណងជំងឺចិត្តដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានលោកជំទាវ មូរ សុខហួរ ថ្កោលទោសថា ជាការលើកទឹកចិត្តឲ្យមានប្រពន្ធ័តុលាការមិនឯករាជ្យ ដែលនៅក្រោមគំនាបនយោបាយ។

**»» ០៦ កក្កដា ២០១០** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញផ្សាយទម្រង់បញ្ជីបោះឆ្នោតថ្មី ដែលទើបត្រូវបានធ្វើវិសោធនកម្ម លើចំណុច ៤.២៨.៧.១ និង៤.២៨.៧.២ នៃបទបញ្ជា និងនីតិវិធី សម្រាប់ប្រើប្រាស់ពេលបោះឆ្នោត ដោយបន្ថែមចំណងជើងនៅខាងលើថា «**បញ្ជីបោះឆ្នោតឆ្នាំ... សម្រាប់ការបោះឆ្នោត ឆ្នាំ...**» និងប្រអប់បួនជ្រុង នៅមុខលេងរៀងអ្នកបោះឆ្នោតនីមួយ។ វិសោធនកម្មនេះ ត្រូវបាន ខុមហ្វ្រែល វិភាគថា មិនមានអ្វីដែលធ្វើឲ្យប្រសើរឡើងនៃប្រពន្ធ័បោះឆ្នោតនៅកម្ពុជាទេ ដោយសារបញ្ហាចំបងរបស់ពលរដ្ឋម្ចាស់ឆ្នោតក្នុងការពិនិត្យឈ្មោះ និងចូលរួមការបោះឆ្នោត មិនត្រូវបានដោះស្រាយ។ វិសោធនកម្ម នេះគ្រាន់ជួយសម្រួលកិច្ចការងាររដ្ឋបាលរបស់មន្ត្រីបោះឆ្នោតប៉ុណ្ណោះ តែបន្ទុកក្នុងការពិនិត្យឈ្មោះអ្នកបោះឆ្នោតមិនទាន់បានដោះស្រាយឲ្យសមស្របទេ។


រូបភាព ៖ ខុមហ្វ្រែល (អ្នកបោះឆ្នោតជាច្រើននៅតែ ពិបាករកឈ្មោះរបស់ខ្លួននៅពេលបោះឆ្នោត)



## អភិបាលកិច្ច និងការអភិវឌ្ឍ




**»»០១ កក្កដា ២០១០** ៖ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងកាតកម្ពុជា បានប្រកាសកាលថា ប្រទេសកម្ពុជានឹងបូមប្រេងជាប្រវត្តិសាស្រ្តលើកដំបូងរបស់ខ្លួននៅខែធ្នូ ឆ្នាំ២០១០។ ព័ត៌មាននេះ បានរងនូវការស្វាគមន៍ និងក្តីព្រួយបារម្ភ ពីសំណាក់អង្គការសង្គមស៊ីវិលជាតិ/អន្តរជាតិ និងគណបក្សប្រឆាំង អំពីតម្លាភាពចំពោះការផ្តល់សម្បទានរុករករ៉ែ ការគ្រប់គ្រងប្រាក់ចំណូលពីវិស័យនេះ និងនរណាជាអ្នកទទួលបានផលប្រយោជន៍ពីវិស័យឧស្សាហកម្មថ្មីនេះ ?

**»»២៥ មិថុនា ២០១០** ៖ រដ្ឋាភិបាលប្រកាសគាំទ្រការដំឡើងប្រាក់ឈ្នួលអប្បបរមាចំនួន ៥ ដុល្លារ និងប្រាក់ឧបត្ថម្ភជីវភាពចំនួន ៦ ដុល្លារ បន្ថែមឲ្យគ្រប់ **៦១ ដុល្លារ** ក្នុងមួយខែ ដល់កម្មករកាត់ដេរនៅកម្ពុជា ហើយប្រាក់ឈ្នួលអប្បបរមានេះ អាចនឹងទាមទារ ឲ្យតម្លើងបានម្តងទៀតនៅឆ្នាំ ២០១៣ ប៉ុណ្ណោះ។ លោក **អាត់ ធន់** ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៅកម្ពុជា យល់ថា ប្រាក់ឈ្នួល នេះមិនអនុញ្ញាតឲ្យកម្មករអាចរស់បានទេ លោកទាមទារឲ្យមានការតម្លើងដល់ ចន្លោះអប្បបរមា ពី **៧៥ ដុល្លារ ទៅដល់ ៩៣ ដុល្លារ។**


កម្មកររោងចក្រកាត់ដេរនៅកម្ពុជា



## ឯកសារផលិតដោយ ខុមហ្វ្រែល



### គណៈកម្មការព្រឹត្តិបត្រ

១» លោក **គល់ បញ្ញា** ទីប្រឹក្សាផ្តល់យោបល់
២» លោក **ចន្ទ័ ដារិទ្ធ** ប្រធានព័ត៌មាន និងការផ្សាយ
៣» លោក **ស្រី សុតភ្រ្ត័** អ្នកនិពន្ធ និងរចនាទំព័រ
៤» កញ្ញា **មឿន សុខមុនី** លេខាការផ្សាយព្រឹត្តិបត្រ

អាសយដ្ឋាន៖ ផ្ទះលេខ១៣៩ ផ្លូវ.១២១ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័ ៖ ០២៣ ៨៨៤ ១៥០
ទូរសារ ៖ ០២៣ ៨៨៣ ៧៥០
អ៊ីម៉ែល ៖ comfrel@online.com.kh
គេហទំព័រ ៖ www.comfrel.org
ប្រអប់សំបុត្រ ៖ ១១៤៥

### សេចក្តីជូនដំណឹង

ព្រឹត្តិបត្រ **អ្នកឃ្លាំមើល** នឹងចែកជូនទៅដល់ប្រជាពលរដ្ឋ (ឥតគិតថ្លៃ) នៅទូទាំងប្រទេសកម្ពុជា ដើម្បីបំពេញចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រអ្នកដឹកនាំ ដែលពាក់ពន្ធ័ក្នុងការចូលរួមស្ថាបនា និងអភិវឌ្ឍសង្គមប្រជាធិបតេយ្យ។

ប្រសិនបើលោក អ្នកនាង កញ្ញា មានសំណូមពរ ឬបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រ និងឯកសារផ្សេងៗ ដែលផលិតដោយ ខុមហ្វ្រែល សម្រាប់រក្សាទុក សូមទំនាក់ទំនងមកការិយាល័យខុមហ្វ្រែល តាមអាសយដ្ឋានដូចដែលបានផ្តល់ជូននេះ យើងខ្ញុំនឹងដោះស្រាយជូននូវរាល់បញ្ហារបស់លោក អ្នកនាង កញ្ញា ដោយមេត្រីភាព។

សូមអរគុណ !